


# ដំណើរទស្សនកិច្ចរបស់លោកអភិបាល អូលីវីយេនៅក្រុងព្រះសីហនុ

**17.06.2015**




- ព្រះសហគមន៍ត្រែងត្រយឹង
- ព្រះសហគមន៍កោះកុង

**18.06.2015**



- ព្រះសហគមន៍ស្រែអំបិល

**19.06.2015**



- ព្រះសហគមន៍បឹងតាព្រហ្ម
- ព្រះសហគមន៍កោះខ្យង
- ក្រុមដូមីនីក
- ក្រុមបងស្រីគង្វាលដ៏សប្បុរស
- សាលាបច្ចេកទេសដុនបូស្កូ

**20-21.06.2015**



- ព្រះសហគមន៍កំពង់សោម
- ការប្រជុំបូកសរុបការងារ

រក្សាសិទ្ធិគ្រប់យ៉ាង ©2015
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

# មាតិកា


១-១២.........................................................១៧ មិថុនា ២០១៨

១. ព្រះសហគមន៍ត្រែងត្រយឹង.........................១-៣

២. ព្រះសហគមន៍កោះកុង...............................៤-១២

១៣-២០.........................................................១៨មិថុនា ២០១៨

១. ព្រះសហគមន៍ស្រែអំបិល.............................១៣-២០

២១-៣៦.........................................................១៩ មិថុនា ២០១៨

១. ព្រះសហគមន៍បឹងតាព្រហ្ម..........................២១-២៣

២. ព្រះសហគមន៍កោះខ្យង...............................២៤-២៩

៣. ក្រុមដូមីនីក..............................................៣០-៣១

៤. ក្រុមបងស្រីគង្វាលដ៏សប្បុរស.........................៣២-៣៣

៥. សាលាបច្ចេកទេសដុនបូស្កូ (កំពង់សោម).........៣៤-៣៥

៣៧-៤៨...................................................២០-២១ មិថុនា ២០១៨

១. ព្រះសហគមន៍សន្តមីកាអែលកំពង់សោម...........៣៦-៤៥

២. លទ្ធផលនៃការប្រជុំបូកសរុបការងារ..................៤៦-៤៩

# ព្រះសហគមន៍កាតូលិក

# ត្រែងត្រយឹង

- ព្រះវិហារ ៖ ព្រះសហគមន៍ត្រែងត្រយឹង
- ប្រធានក្រុមប្រឹក្សា ៖ ព្រំ ណាវ
- អប់រំជំនឿ ៖ លោក លេង ហុង
- ទូរស័ព្ទទំនាក់ទំនង ៖ ០៩៧ ៧៣ ៥៧ ០១៤







# ប្រវត្តិព្រះសហគមន៍ត្រែងត្រយឹង

មុនឆ្នាំ២០០៣ មានគ្រីស្តបរិស័ទវៀតណាម មករកស៊ីចិញ្ចឹមជីវិតនៅត្រែងត្រយឹង។ ពួកគេតែងជួបជុំគ្នាអធិដ្ឋានរៀងរាល់ថ្ងៃអាទិត្យ។ក្នុងឆ្នាំ២០០៣លោក ព្រហ្ម ង៉ោ និងលោក ប៉ុន ទឿន បានជំរាប លោកវីរៈជ័យ ស្រ៊ីប្រាម៉ុង អំពីការកើនឡើងចំនួនគ្រីស្តបរិស័ទនៅភូមិត្រែងត្រយឹងនេះ។ លោកបូជាចារ្យ វិរៈជ័យ ក៏បានទៅសួរសុខទុក្ខគេ ស្តាប់អំពីសេចក្តីត្រូវការរបស់គេ។ លោកបានជួលផ្ទះមួយ សម្រាប់ជួបជុំគ្នាអធិដ្ឋាននៅថ្ងៃអាទិត្យ ហើយលោកបានមកថ្វាយអភិបូជាមួយខែម្តង។ ២ឆ្នាំ ក្រោយមក លោកបានទិញដីតូចមួយកន្លែង និងបានប្រមូលថវិការ ជាជំនួយរបស់ក្រុមគ្រួសារដូមីនិកូ ដើម្បីសាងសង់ព្រះវិហារ។

ក្នុងឆ្នាំ២០០៧ព្រះវិហារសន្តម៉ាតាំង នៃព្រះសហគមន៍កាតូលិកត្រែងត្រយឹងបានសាងសង់រួចរាល់ ហើយក្នុងឆ្នាំដដែលនេះ មានបងស្រីនៃក្រុមគ្រួសារដូមីនីកូ បានមកជួយអប់រំជំនឿដល់កុមារ និងយុវជន ថ្នាក់សាលាមត្តេយ្យ និងកម្មវិធីបង្រៀនកាត់ដេរ។ មកដល់សព្វថ្ងៃនេះព្រះសហគមន៍យើងខ្ញុំ មានគ្រីស្តបរិស័ទចំនួន២២គ្រួសារស្មើនឹងចំនួនមនុស្ស៩៥នាក់ស្រី៥១នាក់។ ដោយការជួយជ្រោមជ្រែងពីលោក លេង ហុង និងគ្រីស្តបរិស័ទផ្សេងៗទៀត សកម្មភាព និងកម្មវិធីព្រះសហគមន៍នេះបានបន្តជីវិតរហូតមកដល់ សព្វថ្ងៃនេះ មានដូចជា៖

- *ការជួបជុំគ្នាអធិដ្ឋាន រាល់ថ្ងៃអាទិត្យ*
- *ការអប់រំជំនឿ យុវជន និងកុមារ*
- *ក្រុមយុវជន និងកុមារ ៖ កម្មវិធីអប់រំ អំពីរតម្លៃជីវិត*
- *សាលាមត្តេយ្យ*
- *ការងារសង្គហៈ ការសួរសុខទុក្ខតាមផ្ទះ ជួយអ្នកក្រីក្រ។ល។*







សកម្មភាពរបស់លោកអភិបាលក្នុងដំណើរទស្សនកិច្ចនៅព្រះសហគមន៍ត្រែងត្រយឹង



# ព្រះសហគមន៍កាតូលិក

# កោះកុង




- **ព្រះវិហារ៖** ព្រះសហគមន៍កោះកុង
- **អាសយដ្ឋាន៖** កោះកុង៣១៤ ភូមិ១ សំអាតមានជ័យ កោះកុង
- **ប្រធានក្រុមប្រឹក្សា/អប់រំជំនឿ៖** លេង ស៊ីន
- **ទូរស័ព្ទទំនាក់ទំនង៖** ០៩៧ ៦៦៣ ៩៨ ៩១

# ប្រវត្តិព្រះសហគមន៍កោះកុង

ព្រះសហគមន៍កាតូលិកកោះកុង កើតនៅឆ្នាំ១៩៩៣ ដោយមានគ្រីស្តបរិស័ទកាតូលិកចំនួន៦គ្រួសារ បានមករស់នៅ និងជួបជុំគ្នា នៅក្នុងស្រុកមណ្ឌលសីមាខេត្តកោះកុង។ មួយឆ្នាំកន្លះក្រោយមក រដ្ឋាភិបាលមិនអនុញ្ញាតឲ្យយើងបន្តការជួបជុំគ្នាជាចំហតទៅទៀតទេ ព្រោះគ្មានច្បាប់ច្បាស់លាស់ តែយើងនៅតែនាំគ្នាជួបជុំនៅតាមផ្ទះដោយស្ងាត់ស្ងៀម។ រហូតដល់ឆ្នាំ១៩៩៦ លោកបូជាចារ្យ វិនណេ ដែលទទួលខុសត្រូវនៅព្រះសហគមន៍កំពង់សោម លោកបានមកកោះកុងដើម្បីស្វែងរកគ្រីស្តបរិស័ទ។ នៅឆ្នាំ១៩៩៧ លោកបូជាចារ្យវិនណេ បានទិញដីមួយកន្លែង ដើម្បីសាងសង់ព្រះវិហារមួយ ដាក់ឈ្មោះថា ព្រះវិហារសន្តម៉ាថាយ ដែលយើងមានរហូតមកដល់បច្ចុប្បន្ននេះ។

សព្វថ្ងៃព្រះវិហារសន្តម៉ាថាយមានគ្រីស្តបរិស័ទចំនួន២២គ្រួសារស្មើនឹងចំនួន៦៨នាក់ ទាំងចាស់ទាំងក្មេង ។








សកម្មភាពរបស់លោកអភិបាលក្នុងដំណើរទស្សនកិច្ចនៅព្រះសហគមន៍កោះកុង






# ធម្មទេសនា
# របស់លោកអភិបាលអូលីវីយេឌ្វីតហាស្ទែរ
# ក្នុងឱកាសទស្សនកិច្ចមណ្ឌលសកម្មភាពកំពង់សោម

## (ព្រះសហគមន៍កោះកុង) ថ្ងៃទី ១៧ មិថុនា ២០១៥

បងប្អូនជាទីស្រឡាញ់!

អត្ថបទទី១និងអត្ថបទគម្ពីរដំណឹងល្អហាក់ដូចជាព្រះជាម្ចាស់បានជ្រើសរើសសម្រាប់យើងជាគ្រីស្តបរិស័ទនៅខេត្តកោះកុងនេះ ជាពិសេសក្នុងអត្ថបទទី២ *" អ្នកណាព្រោះតិច អ្នកនោះច្រូតបានតិច រីឯអ្នកដែលព្រោះច្រើនបរិបូរណ៍ នោះនឹងច្រូតបានច្រើនបរិបូរណ៍ដែរ"*។ អំបាញ់មិញ យើងបានស្តាប់របាយការណ៍ថា ព្រះសហគមន៍របស់យើងនៅទីនេះមានគ្នាតិច មិនច្រើនទេ ក៏ប៉ុន្តែអត្ថបទគម្ពីបានថែងថា *" ប្រសិនបើយើងខិតខំធ្វើជាមនុស្សសុចរិត នោះព្រះជាម្ចាស់ណែនាំយើង ឲ្យទៅជាមនុស្សសុចរិតថែមទៀត ប្រសិនបើយើងសាបព្រោះយ៉ាងច្រើន នោះយើងនឹងច្រូតបានច្រើនថែមទៀត "*។ ដូច្នេះ ព្រះបន្ទូលថ្ងៃនេះហាក់ដូចជាចង់ប្រាប់ថា ប្រសិនបើយើងចង់ឲ្យព្រះសហគមន៍រីកចម្រើន នោះយើងត្រូវការសាបព្រោះយ៉ាងច្រើនដែលយើងនឹងបានច្រើនទៅៗ ប្រសិនបើយើងសាបព្រោះតិច នោះយើងនៅតែតិចដដែល។ ដូច្នេះយើងត្រូវការគិតអំពីរបៀបដែលយើងត្រូវសាបព្រោះ ដែលមានន័យថា យើងបង្ហាញពីរបៀបរស់នៅជាគ្រីស្តបរិស័ទ។ នៅខេត្តកោះកុងនេះ ក្រៅពីកន្លែងនេះមានគ្រីស្តបរិស័ទយើងរស់នៅក្នុង ៣ភូមិទៀតដែរ។ទោះបីតាមភូមិនីមួយៗមានតែ ២គ្រួសារ មាន ៥គ្រួសារ ឬ ៨គ្រួសារក៏ដោយ ក៏យើងត្រូវតែសាបព្រោះដែរ គឺយើងត្រូវផ្តល់សក្ខីភាព។

អំបាញ់មិញយើងបានស្តាប់សន្តៈប៉ូល មានប្រសាសន៍ទៅកាន់គ្រីស្តបរិស័ទនៅក្រុងកូរិថូសថាទីមួយ *"ឲ្យយើងចែករំលែកជាមួយអ្នកក្រីក្រ"*និងទីពីរ *"ឲ្យយើងមានរបៀបរស់នៅសុចរិត"*។សេចក្តីទាំងនេះណែនាំយើងឲ្យភ្ញាក់ស្មារតីថា ជីវិតជាគ្រីស្តបរិស័ទត្រូវតែជាជីវិតគំរូដោយសារអ្នកសុចរិតគឺជាមនុស្សដែលមានចិត្តស្មោះដែលស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាមនុស្ស ដែលចេះស្រឡាញ់អ្នកដទៃ ដែលចេះគោរពបងប្អូនឯទៀតៗ ជាមនុស្ស

ដែលរស់នៅក្នុងសង្គមតាមរបៀបល្អជាមនុស្សដែលចេះទទួលខុសទទួលត្រូវ... នោះហើយគឺជាមនុស្សសុចរិត។ ពេលគិតពីមនុស្សសុចរិត ភ្លាមយើងនឹកឃើញដល់សន្ដះយ៉ូសែប ដែលជាមនុស្សសុចរិត ជាអ្នកស្ដាប់ព្រះបន្ទូលព្រះជាម្ចាស់ ជាមនុស្សចេះគោរពធម្មវិន័យ ជាមនុស្សធ្វើកិច្ចការតាមរបៀបត្រឹមត្រូវ ជាមនុស្សដែលមានចិត្តស្មោះ។ ដូច្នេះ នៅតាមកន្លែងដែលយើងរស់នៅទោះបីយើងមានគ្នាតិចក៏ដោយតែបើយើងខិតខំបង្ហាញអំពីអំណរសប្បាយដែលយើងបានទទួលពីព្រះជាម្ចាស់ នោះបន្តិចម្ដងៗសក្ខីភាពរបស់យើងនឹងមានផលផ្លែច្រើន ហើយផលផ្លែនោះកើតឡើងដោយសារព្រះជាម្ចាស់ធ្វើតាមរយៈយើងព្រះអង្គ ធ្វើឲ្យអ្នកដទៃទទួលស្គាល់ព្រះពន្លឺគឺជាព្រះយេស៊ូ។ យើងត្រូវការគិតថែមទៀត តើធ្វើដូច ម្ដេចដើម្បីទៅជាមនុស្សសុចរិត ? ធ្វើដូចម្ដេចដើម្បីរស់នៅតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ?

អត្ថបទគម្ពីរថ្ងៃនេះ មានចំណុចពីរដ៏សំខាន់ ទី១ ឲ្យយើងជួយអ្នកដទៃ ជួយអ្នកក្រីក្រ ឲ្យយើងចែកទាន ធ្វើអំពើល្អដល់អ្នកដទៃ ចែករំលែកសមត្ថភាពរបស់យើងដល់អ្នកដទៃ។ ត្រូវគិតថា ទោះបីយើងម្នាក់ៗអត់មានឈ្មោះក្នុងក្រុមសង្ឃហៈជាផ្លូវការមែន ប៉ុន្តែនៅក្នុងរបៀបដែលយើងរស់នៅ គឺតាមកន្លែងធ្វើការ នៅសាលា នៅពេលយើងជួបជាមួយអ្នកដទៃ នោះយើងត្រូវចេះបើកភ្នែក ដើម្បីបង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ដល់គេ។ ប្រសិនបើយើងចង់ឲ្យព្រះសហគមន៍របស់យើងមានវត្តមានជាក់ស្ដែងនោះ យើងត្រូវតែសម្ដែងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ដោយមិនដើម្បីទទួលរង្វាន់ បំណ្ណសរសើរ ឬដើម្បីទទួលមេដាយទេ ប៉ុន្តែដើម្បីគាប់ព្រះហឫទ័យព្រះជាម្ចាស់ ដែលព្រះអង្គឈ្វេងយល់គ្រប់កិច្ចការដែលយើងធ្វើ ទោះបីយើងធ្វើដោយស្ងៀមស្ងាត់គ្មានគេដឹងក៏ដោយ។ នៅក្នុងផ្សារកោះកុងយើងនេះមិនខ្វះអ្នកក្រីក្រទេ ទាំងចាស់ជរា ក្មេងអនាថា អ្នកជំងឺគ្មានទីពឹងក៏មានដែរ ដូច្នេះ យើងជាគ្រីស្តបរិស័ទត្រូវចេះបើកភ្នែកចេះរិះគិតរករបៀបដើម្បីផ្ដល់សក្ខីភាពមិនមែនដើម្បីទាក់ទាញឲ្យគេមកព្រះវិហារយើងនោះទេ ប៉ុន្តែ ទី១ គឺយើងត្រូវតែទៅដល់កន្លែងគេ ដូចអ្នកសាម៉ារីគាត់ធ្វើដំណើរទៅឆ្ងាយ គាត់ឃើញម្នាក់ដែលត្រូវរបួស ក្រោយមកគាត់សុខចិត្តចុះពីរទេះរបស់គាត់ទៅលើកអ្នករបួសនិងលាងរបួសឲ្យគេ គាត់ថែរក្សាគេ ដោយយកចិត្តទុកដាក់ និងទោះបីពេលវេលាខ្លីគាត់សុខចិត្តលើកអ្នករបួសនេះ ដាក់លើរទេះសេះរបស់គាត់ដើម្បីជូនគេទៅផ្ទះសំណាក់។ នៅទីនោះគាត់ចេញលុយដើម្បីព្យាបាល និងប្រសិនបើថ្លៃ

បងប្អូនជាទីស្រឡាញ់!

អត្ថបទទី១និងអត្ថបទគម្ពីរជំណឹងល្អហាក់ដូចជាព្រះជាម្ចាស់បានជ្រើសរើសសម្រាប់យើងជាគ្រីស្តបរិស័ទនៅខេត្តកោះកុងនេះ ជាពិសេសក្នុងអត្ថបទទី២ " *អ្នកណាព្រោះតិច អ្នកនោះច្រូតបានតិច រីឯអ្នកដែលព្រោះច្រើនបរិបូរណ៍ នោះនឹងច្រូតបានច្រើនបរិបូរណ៍ដែរ*"។ អំបាញ់មិញ យើងបានស្តាប់របាយការណ៍ថា ព្រះសហគមន៍របស់យើងនៅទីនេះមានគ្នាតិច មិនច្រើនទេ ក៏ប៉ុន្តែអត្ថបទគម្ពីបានចែងថា " *ប្រសិនបើយើងខិតខំធ្វើជាមនុស្សសុចរិត នោះព្រះជាម្ចាស់ណែនាំយើង ឲ្យទៅជាមនុស្សសុចរិតថែមទៀត ប្រសិនបើយើងសាបព្រោះយ៉ាងច្រើន នោះយើងនឹងច្រូតបានច្រើនថែមទៀត* "។ ដូច្នេះ ព្រះបន្ទូលថ្ងៃនេះហាក់ដូចជាចង់ប្រាប់ថា ប្រសិនបើយើងចង់ឲ្យព្រះសហគមន៍រីកចម្រើន នោះយើងត្រូវការសាបព្រោះយ៉ាងច្រើនដែលយើងនឹងបានច្រើនទៅៗ ប្រសិនបើយើងសាបព្រោះតិច នោះយើងនៅតែតិចដដែល។ ដូច្នេះយើងត្រូវការគិតអំពីរបៀបដែលយើងត្រូវសាបព្រោះ ដែលមានន័យថា យើងបង្ហាញពីរបៀបរស់នៅជាគ្រីស្តបរិស័ទ។ នៅខេត្តកោះកុងនេះ ក្រៅពីកន្លែងនេះមានគ្រីស្តបរិស័ទយើងរស់នៅក្នុង ៣ភូមិទៀតដែរ។ទោះបីតាមភូមិនីមួយៗមានតែ ២គ្រួសារ មាន ៥គ្រួសារ ឬ ៨គ្រួសារក៏ដោយ ក៏យើងត្រូវតែសាបព្រោះដែរ គឺយើងត្រូវផ្តល់សក្ខីភាព។

អំបាញ់មិញយើងបានស្តាប់សន្តៈប៉ូល មានប្រសាសន៍ទៅកាន់គ្រីស្តបរិស័ទនៅក្រុងកូរិថូសថា ទីមួយ "*ឲ្យយើងចែករំលែកជាមួយអ្នកក្រីក្រ*"និងទីពីរ "*ឲ្យយើងមានរបៀបរស់នៅសុចរិត*"។សេចក្តីទាំងនេះណែនាំយើងឲ្យភ្ញាក់ស្មារតីថា ជីវិតជាគ្រីស្តបរិស័ទត្រូវតែជាជីវិតគំរូដោយសារអ្នកសុចរិតគឺជាមនុស្សដែលមានចិត្តស្មោះដែលស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាមនុស្ស ដែលចេះស្រឡាញ់អ្នកដទៃ ដែលចេះគោរពបងប្អូនឯទៀតៗ ជាមនុស្សដែលរស់នៅក្នុងសង្គមតាមរបៀបល្អជាមនុស្សដែលចេះទទួលខុសទទួលត្រូវ… នោះហើយគឺជាមនុស្សសុចរិត។ ពេលគិតពីមនុស្សសុចរិត ភ្លាមយើងនឹកឃើញដល់សន្តៈយ៉ូសែបដែលជាមនុស្សសុចរិត ជាអ្នកស្តាប់ព្រះបន្ទូលព្រះជាម្ចាស់ ជាមនុស្សចេះគោរពធម្មវិន័យជាមនុស្សធ្វើកិច្ចការតាមរបៀបត្រឹមត្រូវ ជាមនុស្សដែលមានចិត្តស្មោះ។ ដូច្នេះ នៅតាមកន្លែងដែលយើងរស់នៅទោះបីយើងមានគ្នាតិចក៏ដោយតែបើយើងខិតខំបង្ហាញអំពីអំណរសប្បាយដែលយើងបានទទួលពីព្រះជាម្ចាស់ នោះបន្តិចម្តងៗសក្ខីភាពរបស់យើងនឹង

មានផលផ្លែច្រើន ហើយផលផ្លែនោះកើតឡើងដោយសារព្រះជាម្ចាស់ធ្វើតាមរយៈយើង ព្រះអង្គ ធ្វើឲ្យអ្នកដទៃទទួលស្គាល់ព្រះពន្លឺគឺជាព្រះយេស៊ូ។ យើងត្រូវការគិតថែមទៀត តើធ្វើដូច ម្ដេចដើម្បីទៅជាមនុស្សសុចរិត? ធ្វើដូចម្ដេចដើម្បីរស់នៅតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់?

អត្ថបទគម្ពីរថ្ងៃនេះ មានចំណុចពីរដ៏សំខាន់ ទី១ ឲ្យយើងជួយអ្នកដទៃ ជួយអ្នកក្រីក្រ ឲ្យយើងចែកទាន ធ្វើអំពើល្អដល់អ្នកដទៃ ចែករំលែកសមត្ថភាពរបស់យើងដល់អ្នកដទៃ។ ត្រូវគិតថា ទោះបីយើងម្នាក់ៗអត់មានឈ្មោះក្នុងក្រុមសង្គហៈជាផ្លូវការមែន ប៉ុន្តែនៅក្នុងរបៀបដែលយើងរស់នៅ គឺតាមកន្លែងធ្វើការ នៅសាលា នៅពេលយើងជួបជាមួយអ្នកដទៃ នោះយើងត្រូវចេះបើកភ្នែក ដើម្បីបង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ដល់គេ។ ប្រសិនបើយើងចង់ឲ្យព្រះសហគមន៍របស់យើងមានវត្តមានជាក់ស្ដែងនោះ យើងត្រូវតែសម្ដែងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ដោយមិនដើម្បីទទួលរង្វាន់ ប័ណ្ណសរសើរ ឬដើម្បីទទួលមេដាយទេ ប៉ុន្តែដើម្បីគាប់ព្រះហឫទ័យព្រះជាម្ចាស់ ដែលព្រះអង្គឈ្វេងយល់គ្រប់កិច្ចការដែលយើងធ្វើ ទោះបីយើងធ្វើដោយស្ងៀមស្ងាត់គ្មានគេដឹងក៏ដោយ។ នៅក្នុងផ្សារកោះកុងយើងនេះមិនខ្វះអ្នកក្រីក្រទេ ទាំងចាស់ជរា ក្មេងអនាថា អ្នកជំងឺគ្មានទីពឹងក៏មានដែរ ដូច្នេះយើងជាគ្រីស្តបរិស័ទត្រូវចេះបើកភ្នែកចេះរិះគិតរករបៀបដើម្បីផ្ដល់សក្ខីភាពមិនមែនដើម្បីទាក់ទាញឲ្យគេមកព្រះវិហារយើងនោះទេ ប៉ុន្តែ ទី១ គឺយើងត្រូវតែទៅដល់កន្លែងគេ ដូចអ្នកសាម៉ារីគាត់ធ្វើដំណើរទៅឆ្ងាយ គាត់ឃើញម្នាក់ដែលត្រូវរបួស ក្រោយមកគាត់សុខចិត្តចុះពីរទេះរបស់គាត់ទៅលើកអ្នករបួសនិងលាងរបួសឲ្យគេ គាត់ថែរក្សាគេ ដោយយកចិត្តទុកដាក់ និងទោះបីពេលវេលាខ្លីគាត់សុខចិត្តលើកអ្នករបួសនេះ ដាក់លើរទេះសេះរបស់គាត់ ដើម្បីជូនគេទៅផ្ទះសំណាក់។ នៅទីនោះគាត់ចេញលុយដើម្បីព្យាបាល និងប្រសិនបើថ្លៃព្យាបាលមិនគ្រប់ទេ ពេលគាត់មកម្ដងទៀត គាត់នឹងសងឲ្យគ្រប់ចំនួន។ លោកឪពុកសុនពូកែធ្វើកិច្ចការនេះ រកឃើញអ្នកជំងឺគ្រប់ទីកន្លែងដើម្បីយកទៅមណ្ឌលសុខភាព។ នេះជារបៀបដែលយើងត្រូវតែធ្វើ ដើម្បីបន្តិចម្ដងៗឲ្យព្រះសហគមន៍របស់យើង ទៅជាព្រះសហគមន៍ដែលចាក់ឫសនៅកន្លែងដែលយើងរស់នៅ។

ទី២ ការអធិដ្ឋានសំខាន់ណាស់ ប្រសិនបើគ្រីស្តបរិស័ទយើងមិនដែលជួបជុំគ្នាអធិដ្ឋាន តើធ្វើដូចម្ដេចដើម្បីយើងអាចបង្កើនទំនាក់ទំនងជាមួយព្រះយេស៊ូ និងទទួលកម្លាំងពីព្រះអង្គ

ទៅស្រឡាញ់គេ?។ ដូច្នេះកន្លែងនេះ ជាកន្លែងដែលយើងអាចចេញចូលបានរាល់ថ្ងៃ ដើម្បីអធិដ្ឋាន ប្រសិនបើយើងនៅឆ្ងាយមកមិនបាន នោះរាល់ថ្ងៃកុំភ្លេចព្រះជាម្ចាស់ដោយសូត្រធ្មុំ សូត្របពិត្រព្រះនាងម៉ារី ឱព្រះបិតា និងអរគុណព្រះជាម្ចាស់ ដែលបន្តិចម្តងៗនាំឲ្យជីវិតរបស់យើងកាន់តែជិតស្និទ្ធឡើងថែមទៀតជាមួយព្រះយេស៊ូ។ ប៉ុន្តែព្រះយេស៊ូបានសូមឲ្យយើងប្រយ័ត្ន មិនត្រូវអធិដ្ឋានដើម្បីឲ្យគេឃើញ ឬដឹងថាយើងចូលព្រះវិហាររាល់ថ្ងៃ ឬថាយើងជាមនុស្សល្អនោះទេ។ សំខាន់ណាស់ រាល់ថ្ងៃទោះបីយើងទៅផ្សារ យើងជិះម៉ូតូ យើងធ្វើការ នោះត្រូវតែមានកន្លែងមួយនៅក្នុងចិត្តរបស់យើង ដើម្បីនឹកឃើញដល់ព្រះជាម្ចាស់ ដល់ព្រះនាងម៉ារី ដល់ព្រះយេស៊ូដើម្បីតែមួយជាមួយព្រះអង្គ។ បន្តិចទៀតកូនពីរនាក់ដែលទទួលព្រះកាយព្រះគ្រីស្ត គេនឹងមានបទពិសោធន៍នេះដែរ។ រាល់ដងនៅពេលថ្វាយអភិបូជា យើងទទួលព្រះយេស៊ូនៅក្នុងជីវិតរបស់យើង យើងទៅជាតែមួយជាមួយព្រះអង្គ នេះជាការអាថ៌កំបាំងដែលគ្មាននរណាអាចមើលឃើញទេ អ្នកដទៃគេអត់យល់ទេ ប្រសិនបើគេបានឃើញយើងកំពុងទទួលព្រះកាយក្នុងពេលថ្វាយអធិបូជា។ ចំពោះយើង យើងដឹងថា ពេលនោះគឺយើងកំពុងនៅជាមួយព្រះយេស៊ូ ជាផ្លូវតែមួយជាមួយព្រះអង្គ ហើយព្រះអង្គជាកម្លាំងរបស់យើង។ ដូច្នេះ ព្រះសហគមន៍របស់យើងតូចធំវាមិនសំខាន់ទេ សំខាន់គឺយើងម្នាក់ៗយល់សេចក្តីនេះយ៉ាងច្បាស់ ដែលជាកម្លាំងមួយសម្រាប់យើង។ លោកបូជាចារ្យតាមព្រះសហគមន៍នីមួយៗ លោកគឺជាគង្វាលដ៏សប្បុរសរបស់យើង ប៉ុន្តែទោះបីលោកមិនបានស្នាក់នៅទីនេះរហូត មិនអាចមករាល់អាទិត្យ មិនអាចចូលរួមគ្រប់សកម្មភាពប្រចាំថ្ងៃនៅទីនេះក៏ដោយ ក៏យើងជាគ្រីស្តបរិស័ទត្រូវតែចេះថែរក្សាព្រះសហគមន៍របស់ខ្លួន គឺយើងជាអ្នកដែលទទួលខុសទទួលត្រូវ ជាអ្នកដែលមានយោបល់ ជាអ្នកដែលមានសេចក្តីក្លាហាន ជាអ្នកដែលបង្ហាញថាព្រះយេស៊ូនៅជាមួយខ្ញុំ ព្រះអង្គស្រឡាញ់ខ្ញុំ ហើយខ្ញុំចង់រស់នៅដើម្បីឲ្យអ្នកដទៃទទួលព្រះយេស៊ូ ទទួលព្រះអង្គតាមរបៀបដែលព្រះអង្គលាងរបួសឲ្យគេ និងបម្រើគេ។ សូមកុំឲ្យយើងចង្អៀតចិត្តគិតថា អត់មានលោកយើងធ្វើអីអត់បាន។ សព្វថ្ងៃមានកន្លែងជាច្រើន ដែលមិនមានលោកបូជាចារ្យថ្វាយអភិបូជារាល់អាទិត្យ កន្លែងខ្លះក្នុងមួយឆ្នាំជួបលោកតែពីរឬបីដងប៉ុណ្ណោះ ដូច្នេះយើងនៅទីនេះ មានសំណាងជាងគេទៅទៀត។

ប្រសិនបើយើងនៅទីនេះជាអ្នកបម្រើដែលចេះស្រឡាញ់ នោះបន្តិចម្តងៗព្រះសហគមន៍របស់យើងនឹងទៅជា ព្រះសហគមន៍ដែលស្អាតទៅៗ ដោយព្រះជាម្ចាស់គង់នៅជាមួយយើង និងជួយយើង។ តាមពិតយើងមិនមានកម្លាំងអ្វីទេ ដូច្នេះយើងត្រូវផ្ញើជីវិតលើព្រះជាម្ចាស់ ដ្បិតមានតែព្រះអង្គទេដែលអាចជួយយើងបានដូចយើងបានស្តាប់អត្ថបទទីមួយថា *" មនុស្សសុចរិតដោយសារផ្ញើជីវិតលើព្រះជាម្ចាស់ "* ដូច្នេះយើងត្រូវស្រឡាញ់ព្រះជាម្ចាស់ថែមទៀត យើងត្រូវចេះលើកលែងទោសឲ្យគេ នោះព្រះជាម្ចាស់មិនលះបង់ចោលយើងឡើយ។ ព្រះសហគមន៍របស់យើងនឹងទៅជាព្រះសហគមន៍ដែលផ្តល់សេចក្តីសង្ឃឹមកាន់តែខ្លាំងឡើង ទៅជាព្រះសហគមន៍របស់ព្រះយេស៊ូ ដែលផ្តល់ពន្លឺសម្រាប់អ្នកដទៃវាអាស្រ័យ លើយើងម្នាក់ៗទៅជាគ្រីស្តបរិស័ទដែលរឹងមាំដែរ។ ទីតាំងរបស់យើងនៅទីនេះល្អណាស់ ដោយសារយើងនៅចំកណ្តាលទីរួមខេត្ត នៅជិតសាលាខេត្ត នៅជិតមន្ទីរវប្បធម៌ និងនៅជិតកីឡាដ្ឋាន ដូច្នេះពេលគេមកលេងកីឡា អាចជាពេលវេលាមួយឲ្យយើងបង្កើតទំនាក់ទំនង...។

ចូរយើងរួមគ្នាថែមទៀត រកមធ្យោបាយខ្លះៗដើម្បីបន្តប្រកាសដំណឹងល្អតាមរបៀបដែលព្រះយេស៊ូមានព្រះបន្ទូលថា ៖ *" ត្រូវស្រឡាញ់អ្នកតូចតាច អ្នកក្រីក្រ និង អធិដ្ឋាន "* ប៉ុន្តែមិនមែនដើម្បីទទួលរង្វាន់ទេ គឺដើម្បីឲ្យគាប់ព្រះហឫទ័យព្រះបិតា ដែលស្រឡាញ់យើង ហើយយើងនឹងទទួលកម្លាំងថែមទៀតពីព្រះអង្គ។ ដូច្នេះ យើងអរព្រះគុណព្រះជាម្ចាស់ យើងបន្តអភិបូជារបស់យើងដោយសូមព្រះជាម្ចាស់គង់នៅជាមួយយើង ដើម្បីឲ្យយើងទៅជាព្រះសហគមន៍របស់ព្រះអង្គ ព្រះសហគមន៍ដ៏វិសុទ្ធ៕ អាម៉ែន។

# ព្រះសហគមន៍កាតូលិក

# ស្រែអំបិល

- **ព្រះវិហារ៖** ព្រះវិហារសន្តីតេរេសាស្រែអំបិល
- **ប្រធានក្រុមប្រឹក្សា៖** លោក លី
- **អប់រំជំនឿ៖** បងស្រី យឺន ជូលីណា លីអុក
- **ទូរស័ព្ទទំនាក់ទំនង៖** ០៨៦ ៤២៧ ៨១១



# ប្រវត្តិព្រះវិហារសន្តីតេរេសា
# នៃព្រះសហគមន៍កាតូលិក នៅស្រែអំបិល

នៅចន្លោះឆ្នាំ១៩៩៥ដល់១៩៩៦ មានគ្រីស្តបរិសទ័មួយភាគតូចបានចូលមករស់នៅក្នុងស្រុកស្រែអំបិល។ ពួកគេបានចាប់ផ្តើមមកជួបជុំគ្នា ដើម្បីអធិដ្ឋានជាមួយគ្នាជារៀងរាល់ថ្ងៃអាទិត្យនៅក្នុងផ្ទះរបស់លោកធូម យ៉ាង។

មួយឆ្នាំក្រោយមកពួកគេបានជូនដំណឹងមកលោកអភិបាលអ៊ីវ៉ាមូសជាអភិបាលភូមភាគភ្នំពេញ អំពីវត្តមាននិងសកម្មភាពផ្សេងៗនៅក្នុងព្រះសហគមន៍នៅទីនេះ។ ពេលលោកអភិបាលបានទទួលដំណឹងនេះលោកក៏បានទៅចុះសួរសុខទុក្ខបងប្អូនហើយក៏បានបញ្ជូនលោកបូជាចារ្យវិន័យ (ជាបូជាចារ្យនៃព្រះសហគមន៍កាតូលិកសន្តមីកាអែល នៅកំពង់សោម) ឲ្យមកណែនាំពួកគេ រហូតមកដល់ឆ្នាំ២០០០។ ក្រោយមកលោកអភិបាលបានចាត់លោកបូជាចារ្យថ្មីមួយរូបទៀតនាម វីរៈ ឆ័យ ជាបូជាចារ្យប្រចាំព្រះសហគមន៍កាតូលិកសន្តមីកាអែលនៅកំពង់សោម ដើម្បីទទួលខុសត្រូវបន្តពីលោកបូជាចារ្យវិន័យ។

ក្នុងឆ្នាំ២០០៧ក្រុមបងស្រីដូមីនីកូបានមកជួយលោកបូជាចារ្យហើយបានកសាងព្រះសហគមន៍ ដោយអប់រំជំនឿ និងសួរសុខទុក្ខបងប្អូន។ នៅឆ្នាំ ២០០៩ លោកបូជាចារ្យ វិរៈឆ័យ បានទិញផ្ទះមួយកន្លែងតែវាមានសភាពឧត្រឧព្រមបន្តិចទោះជា យ៉ាងណាក៏ដោយ គ្រីស្តបរិស័ទ បានជួយគ្នារៀបចំ និងការជួសជុលសាជាថ្មី។

ដោយសារតែពីដើម គ្រីស្តបរិស័ទបានជួបជុំគ្នានិងថ្វាយអភិបូជា និងបង្រៀនអប់រំជំនឿនៅតាមផ្ទះរបស់គ្រីស្តបរិស័ទ។ ប៉ុន្តែក្រោយពីបានទិញផ្ទះនេះមក គ្រីស្តបរិស័ទទាំងអស់គ្នាមានកន្លែងមួយសំរាប់ជួបជុំគ្នាអធិដ្ឋានផងដែរ។ ហើយផ្ទះនេះ ក៏ជាកន្លែងស្នាក់នៅរបស់ក្រុមបងស្រីផងដែរ។ ហើយនៅក្នុងមួយសប្តាហ៍មាន ២-៣ ថ្ងៃ ដែលក្រុមបងស្រីមានសកម្មភាពជាមួយគ្រីស្តបរិសទ័ និងបង្កើតសកម្មភាពមួយចំនួនទៀតសម្រាប់យុវជននិងកុមារ (សម្រាប់ទាំងអ្នកកាន់សាសនាព្រះពុទ្ធ និងសាសនាគ្រីស្ត)។

ក្នុងឆ្នាំ ២០១០លោកបូជាចារ្យ វិរៈ ឆ័យ បានទិញដី១ហិកតា ដែលមានទីតាំងនៅភូមិខ្លុង ក្នុងគោលបំណងដើម្បីផ្តល់ជូននូវសកម្មភាពផ្សេងៗ និងបម្រើបងប្អូននៅក្នុងតំបន់នោះ និងមានសាលាមតេយ្យព្រមទាំងមានកម្មវិធីផ្សេងៗសម្រាប់កុមារ។

ក្នុងឆ្នាំ២០១២ លោកពុក អ៊ុនសុន ដែលជាបូជាចារ្យថ្មីបានមកជំនួសលោកបូជាចារ្យវិរៈឆ័យ ហើយបានមើលការខុសត្រូវព្រះហាគមន៍កាតូលិកសន្តៈមីកាអេល ហើយនិងមានលោកបូជាចារ្យឌេនីសដេលជាជំនួយការបានរៀបចំលិខិតសុំអនុញ្ញាតអោយមានការសាងសង់អគារមួយ សម្រាប់កម្មវិធីរបស់យើង ដើម្បីប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងបង្ហាញជំនឿដល់បងប្អូនឯទៀតក្នុងភូមិបានស្គាល់។

នៅឆ្នាំ២០១៣ លោកពុកចន បានជួយនៅព្រះសហាគមន៍កាតូលិកសន្តមីកាអែល នៅកំពង់សោមហើយបានមកថ្វាយអភីបូជានៅតាមភូមិ ជាពិសេសលោកបានមកថ្វាយអភិបូជានៅស្រែអំបិល ជារៀងរាល់ថ្ងៃអាទិត្យ។

នៅឆ្នាំ២០១៤ខែ១១អគារនោះត្រូវបានចាប់ផ្តើមសាងសង់។ក្រោយមកមានលោកបូជាចារ្យ ដាមីអនេ បានមកជួយ និងថ្វាយអភិបូជាជារៀងរាល់សប្តាហ៍ផងដែរ។ ហើយបច្ចុប្បន្ននេះអគារនោះសាងសង់ពុំទាន់រួចរាល់ទេ តែខ្ញុំសង្ឃឹមថាអគារនោះ និងសាងសង់រួចរាល់ក្នុងពេលឆាប់ៗនាពេលខាងមុខ...។

សព្វថ្ងៃមានចំនួនគ្រីស្តបរិសទ័១៤គ្រួសារ ស្មើរ៣៨នាក់ មនុស្សពេញវ័យ២២នាក់ យុវជន៣នាក់ កុមារ១៣នាក់។







លោកអភិបាល លោកបូជាចារ្យ ថ្វាយអភិបូជារួមគ្នាជាមួយគ្រីស្តបរិស័ទ




សកម្មភាពរបស់លោកអភិបាលក្នុងដំណើរទស្សនកិច្ចនៅព្រះសហគមន៍ស្រែអំបិល





# ធម្មទេសនា
# របស់លោកអភិបាលអូលីវីយេដឺតហាស្ទែរ
# ក្នុងឱកាសទស្សនកិច្ចមណ្ឌលសកម្មភាពកំពង់សោម

## (ព្រះសហគមន៍ស្រែអំបិល) ថ្ងៃទី ១៩ មិថុនា ២០១៥

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងបានស្តាប់អត្ថបទមួយ ដែលព្រះយេស៊ូកំពុងបង្រៀនក្រុមសាវ័កឲ្យគេចេះអធិដ្ឋានជាពាក្យអធិដ្ឋាន មួយយ៉ាងពិសេសគឺ *"ឱព្រះបិតាយើងខ្ញុំដែលគង់នៅស្ថានបរមសុខអើយ..."* យើងរាល់ថ្ងៃក៏សូត្រពាក្យអធិដ្ឋាននេះដែរ។ ដូច្នេះ ពេលយើងស្តាប់អត្ថបទនេះ គឺហាក់បីដូចជាព្រះយេស៊ូកំពុងបង្រៀនយើងនៅទីនេះឲ្យចេះអធិដ្ឋានថែមទៀត។ ខ្ញុំចង់ឲ្យបងប្អូនចាំសេចក្តីដ៏សំខាន់ ៤នៅក្នុងពាក្យអធិដ្ឋាននេះគឺៈ

ទីមួយ *"យើងមិនអធិដ្ឋានទៅរកព្រះជាម្ចាស់ទូទៅទេ"*គឺយើងអធិដ្ឋានទៅរកព្រះបិតា។ ព្រះយេស៊ូណែនាំឲ្យយើងយល់ថាព្រះជាម្ចាស់គឺជាឪពុកជាប៉ារបស់យើង។បើព្រះជាម្ចាស់ជាប៉ារបស់យើងមានន័យថា ព្រះអង្គការពារយើងគ្រប់ពេលវេលា។ យើងមានពិសោធអំពីឪពុកស្រឡាញ់កូន ឪពុកថែរក្សាក្រុមគ្រួសារ ដូច្នេះយើងក៏អាចដឹងពីព្រះជាម្ចាស់ ដែលស្រឡាញ់យើងនិងថែរក្សាយើងដែរ។ នៅទីនេះ យើងនៅមានគ្នាតិច ដែលពេលខ្លះនាំឲ្យយើងមានអារម្មណ៍ថាឯកា គ្មាននរណាគាំទ្រយើង ប៉ុន្តែតាមពិតមិនមែនទេ គឺយើងមានព្រះជាម្ចាស់ដែលគាំទ្រ ដែលស្រឡាញ់ ដែលថែរក្សាយើង។ ព្រះជាម្ចាស់ស្រឡាញ់យើង ព្រះអង្គថែរក្សាយើង ដោយសារព្រះអង្គបានបង្កើតយើង។ ម្យ៉ាងទៀត ព្រះជាម្ចាស់ជាព្រះបិតាក៏មានន័យដែរថា យើងទាំងអស់គ្នាជាមហាគ្រួសារមួយ ព្រះបិតាមិនមែនជាបិតាតែរបស់អ្នកនេះឬអ្នកនោះទេ ប៉ុន្តែព្រះអង្គជាព្រះបិតារបស់យើងទាំងអស់គ្នា ដូច្នេះយើងទាំងអស់គ្នាជាបងប្អូនគ្នា។ ការណ៍នេះ ណែនាំយើងឲ្យយល់ខ្លះៗអំពីអត្ថន័យនៃព្រះសហគមន៍ ដែលជាមហាគ្រួសារមួយចេះស្រឡាញ់គ្នាទៅវិញទៅមក ចេះជួយគ្នាទៅវិញទៅមក និងចេះលើកទឹកចិត្តគ្នាទៅវិញទៅមក។

ទីពីរ " *ព្រះយេស៊ូណែនាំឲ្យគេស្គាល់ព្រះនាមរបស់ព្រះបិតា* " ដូច្នេះយើងជាគ្រីស្ទបរិស័ទក៏មានតួនាទីធ្វើឲ្យមនុស្សឯទៀតៗអាចស្គាល់ព្រះបិតាដែរ។ ព្រះបិតា មិនមែនជាព្រះបិតារបស់យើងតែប៉ុណ្ណោះ ប៉ុន្តែជាព្រះបិតាសម្រាប់គេ ដែលមិនមែនជាគ្រីស្ទបរិស័ទដែរ។នៅទីនេះមានគ្រីស្ទបរិស័ទរស់នៅចំនួន៣៣គ្រួសារប៉ុន្តែមានចំនួនគ្រួសារច្រើនទៀតដែលមិនស្គាល់ព្រះនាមរបស់ព្រះបិតា និងព្រះនាមរបស់ព្រះយេស៊ូ។ ដូច្នេះ យើងមានការងារមួយពិសេស ធ្វើយ៉ាងណាដើម្បីបង្ហាញឲ្យគេឃើញព្រះនាមរបស់ព្រះយេស៊ូ ឲ្យគេចាប់អារម្មណ៍អំពីយើងដែលជាព្រះសហគមន៍។ នៅទីនេះ យើងមានកន្លែងដើម្បីអធិដ្ឋានបន្តិចទៀត យើងប្តូរទីកន្លែងទៅលើភ្នំ ដែលយើងនឹងមានសាលាមត្តេយ្យ មានកម្មវិធីកាត់ដេរ កម្មវិធីអក្ខរកម្ម ដែលទាំងអស់នេះជាឱកាសផ្សេងៗ ដើម្បីឲ្យយើងបង្ហាញព្រះនាមព្រះបិតារបស់យើង ដែលស្រឡាញ់មនុស្សទាំងអស់។ កូនៗមត្តេយ្យដែលរៀននៅសាលារបស់យើង យុវនារីដែលរៀនកាត់ដេរ យុវជនដែលរៀនអក្ខរកម្ម មិនមែនសុទ្ធតែជាគ្រីស្ទបរិស័ទទេ គឺយើងត្រូវតែបើកទ្វារឲ្យបងប្អូនឯទៀតចូលមក ដើម្បីជាឱកាសមួយបង្ហាញពីរបៀបដែលព្រះជាម្ចាស់ស្រឡាញ់យើង និងស្រឡាញ់អ្នកគេដែរ។

ទីបី *សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ* ។ ដើម្បីរស់រានមានជីវិតយើងជាគ្រីស្តបរិស័ទ ត្រូវតែទូលសូមទៅព្រះបិតា ដោយសារព្រះបិតាស្រឡាញ់យើង ព្រះអង្គថែរក្សាយើងគ្រប់ពេលវេលា ព្រះអង្គមិនដែលលះបង់ចោលយើងឡើយ។ ប្រសិនបើយើងអត់ដែលទូលសូមអ្វីសោះ នោះយើងក៏អត់ដែលទទួលអ្វីសោះដែរ។ ប៉ុន្តែយើងមិនត្រូវទូលសូមនូវអ្វីដែលគ្មានអត្ថន័យដូចជា សូមឲ្យយើងទៅជាមនុស្សដែលមានអំណាចមានឡាន មានអ្វីៗពិសេសតាមរបៀបមនុស្សលោកិយនោះទេ យើងត្រូវទូលសូមដើម្បីទៅជាគ្រីស្តបរិស័ទល្អ ដើម្បីទៅជាមនុស្សល្អមានសេចក្តី ស្រឡាញ់មកពីព្រះបិតា។ សន្តប៉ូលមានប្រសាសន៍នៅក្នុងអត្ថបទទី១ថា លោកខិតខំជួយអប់រំគេណាស់ លោកខិតខំណែនាំគេឲ្យទៅជាមនុស្សល្អ ដូច្នេះនេះជាអ្វីដែលយើងត្រូវការទូលសូម។ ពេលយើងចេះស្រឡាញ់គ្នាទៅវិញទៅមក នោះជាសញ្ញាមួយបង្ហាញថា យើងជាក្រុមគ្រួសាររបស់ព្រះយេស៊ូដែលចេះស្រឡាញ់គ្នា ចេះជួយគ្នា ផ្តល់កម្លាំងឲ្យគ្នាទៅវិញទៅមក។ ព្រះបិតាគាប់ព្រះហឫទ័យឲ្យយើងទូលសូម ដើម្បីក្លាយជាមនុស្សល្អចេះស្រឡាញ់គ្នាយ៉ាងពិតប្រាកដ។

ទី៤"ឲ្យយើងចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមក ដូចព្រះបិតាលើកលែងទោសឲ្យយើង "  យើងដឹងហើយក្នុងការរស់នៅ យើងតែងតែឈ្លោះគ្នា ជួនកាលយើងស្អប់គេ ប្រកាន់គេ ឈប់និយាយ ឈប់ទាក់ទងនឹងគេ។ ប៉ុន្តែគ្រប់ពេលត្រូវនឹកឃើញថា ព្រះបិតាលើកលែងទោសឲ្យយើងហេតុនេះយើងក៏ត្រូវលើកលែងទោសឲ្យគេដែរ។ ការលើកលែងទោសមិនមែនជាងាយទេ។ ជាទូទៅមនុស្សយើងតែងសងសឹកគ្នា នៅពេលណាគេធ្វើអំពើអត់ល្អមកលើខ្លួននោះ យើងតែងចង់ធ្វើអំពើមិនល្អទៅគេវិញ ពេលណាគេវាយយើងនោះ យើងចង់វាយគេវិញ ពេលណាគេនិយាយដើមយើង នោះយើងនឹងនិយាយដើមគេវិញ...។ ប៉ុន្តែព្រះយេស៊ូមិនសព្វព្រះហឫទ័យឲ្យយើងសងសឹកទេ ព្រះអង្គសូមឲ្យយើងលើកលែងទោសឲ្យគេពេលគេធ្វើបាបយើង គឺឲ្យយើងធ្វើល្អតបទៅវិញ ពេលគេវាយយើងខាងម្ខាងឲ្យយើងបែរម្ខាងទៀតឲ្យគេវាយ យើងមិនត្រូវស្អប់អ្នកដែលស្អប់យើងឡើយ ដូច្នេះតើធ្វើដូចម្តេច ដើម្បីទៅជាសាក្សីនៃការលើកលែងទោសតាមរបៀបព្រះយេស៊ូ?។ សន្តៈប៉ូលធ្លាប់មានប្រសាសន៍ថា គ្រីស្តបរិស័ទត្រូវបានគេមើលឃើញថាជាមនុស្សលីលា ជាមនុស្សវង្វេង ដ្បិតអីពេលគេធ្វើបាបខ្លួនហើយ តែបែរជាលើកលែងទោសឲ្យគេវិញ។ ហេតុនេះហើយដើម្បីកសាងព្រះសហគមន៍របស់យើងនៅស្រែអំបិលនេះ៖ ទី១ ឲ្យនឹកឃើញថាយើងមានព្រះបិតាតែមួយ ដែលជាព្រះបិតារបស់មនុស្សទាំងអស់ និងយើងជាមហាគ្រួសារតែមួយ។ ទី២ ឲ្យយើងណែនាំអ្នកដទៃឲ្យស្គាល់ព្រះនាមរបស់ព្រះបិតារបស់យើង ដោយបង្ហាញមេត្តាករុណានិងសេចក្តីស្រឡាញ់ដល់គេ។ ទី៣ ឲ្យយើងខិតខំទូលសូមនោះ ព្រះបិតានឹងឆ្លើយតប។ ទី៤ ឲ្យយើងចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមក។ ដូច្នេះអ្វីទាំងអស់នេះ នឹងណែនាំឲ្យយើងអាចបង្កើតព្រះសហគមន៍មួយ ជាព្រះសហគមន៍របស់ព្រះយេស៊ូពិតៗ។

ថ្ងៃនេះយើងមានអំណរសប្បាយ ដោយសារព្រះយេស៊ូគង់នៅជាមួយយើង ព្រះអង្គណែនាំឲ្យយើងរស់នៅជាគ្រីស្តទូត ជាសាវ័កគំរូសម្រាប់បងប្អូនឯទៀតៗ។ យើងដឹងថាព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាខ្យល់ ជាកម្លាំង ជាសេចក្តីស្រឡាញ់ ជាព្រះជន្មផ្ទាល់របស់ព្រះជាម្ចាស់ គង់នៅជាមួយយើងដើម្បីឲ្យយើងទៅជាមនុស្សក្លាហាន។ គ្រីស្តបរិស័ទ ដែលមានសេចក្តីក្លាហានជានិច្ច និងមានសេចក្តីសង្ឃឹមជានិច្ច ទោះបីពិបាកចិត្តដូចគេ ទោះបីអស់សង្ឃឹមដូចគេ ឬទោះបីមានរឿងដែលនាំយើងឲ្យមានការឈឺចាប់យ៉ាងណាក្តី ក៏យើង

មានអំណរសប្បាយម្យ៉ាងដោយដឹងថា យើងមានព្រះយេស៊ូគង់នៅជាមួយ ជំរុញយើងឲ្យទៅមុខនិងទៅជាមនុស្សដ៏ប្រសើរបាន។

ដូច្នេះ ចូរយើងទូលសូមព្រះបិតាថែមទៀត ដើម្បីឲ្យយើងទៅជាមហាគ្រួសារមួយដែលគេឃើញនិងនិយាយថា " យើងប្លែក " ។ យើងប្លែកដោយសារយើងចេះស្រឡាញ់គ្នាទៅវិញទៅមក ចេះចែករំលែកសេចក្តីស្រឡាញ់ដល់អ្នកដទៃ។ សូមឲ្យព្រះសហាគមន៍យើងនៅទីនេះទៅជាព្រះសហគន៍មួយរឹងមាំ ពេលយើងទៅកន្លែងថ្មីក៏កាន់តែរឹងមាំថែមទៀត។ ចូរទូលសូមថែមទៀតឲ្យយើងទៅជាគ្រីស្តបរិស័ទរឹងមាំ ទោះបីយើងនៅមានគ្នាតិចក៏ដោយ គឺសូមឲ្យយើងម្នាក់ៗទៅជាគ្រីស្តបរិស័ទលេខ១ ដែលខិតខំស្រឡាញ់គេ ខិតខំជួយគេអស់ពីសមត្ថភាព ខិតខំលើកលែងទោសគេអស់ ពីសមត្ថភាព និងក៏ខិតខំអធិដ្ឋានអស់ពីសមត្ថភាពដែរ។ ចូរបង្រៀនកូនៗឲ្យចេះអធិដ្ឋាន ចេះសូត្រធម៌ឱព្រះបិតា សូត្រធម៌បពិត្រព្រះនាងម៉ារីជាភាសារខ្មែរដែរ។ សូមកុំសូត្រដដែលៗ ដោយមិនដឹងខ្លួន តែពេលសូត្រម្តងៗត្រូវភ្ញាក់ស្មារតីថា ពិតមែនព្រះបិតាស្រឡាញ់ខ្ញុំ ខ្ញុំសប្បាយចិត្តណាស់ ខ្ញុំសូមអរព្រះគុណព្រះបិតាដែលស្រឡាញ់ខ្ញុំ ដើម្បីឲ្យយើងមានកម្លាំងថែមទៀត ក្នុងការកសាងព្រះសហាគមន៍របស់យើង៕ អាម៉ែន។

# ព្រះសហគមន៍កាតូលិក

# បឹងតាព្រហ្ម

- **ព្រះវិហារ៖** ព្រះវិហារបឹងតាព្រហ្ម
- **ប្រធានក្រុមប្រឹក្សា៖** ស សុភ័ណ្ឌ
- **អប់រំជំនឿ៖** បងស្រី អ៊ីប៉ាដូឡាហ្សា សាលវ៉ាស្សន សុភ័ណ្ឌ
- **ទូរស័ព្ទទំនាក់ទំនង៖** ០១៥ ៧៩ ៩១ ០៦៧



# ប្រវត្តិព្រះវិហារសន្ត ដូមីនីកូ នៃព្រះសហគមន៍កាតូលិកបឹងតាព្រហ្ម

នៅឆ្នាំ២០០០ លោក បូជាចារ្យវិរៈជ័យ បានចាត់លោក នូ ចាន់សារឿន ឲ្យទៅអប់រំជំនឿបងប្អូនដែលចង់ស្វែងយល់អំពីគ្រីស្តសាសនា។ លោកចាន់សារឿនបានអប់រំគេរយៈពេលមួយខែ នៅផ្ទះម្តាយក្មេករបស់លោក។ ពេលនោះមានបងប្អូនពីកោះខ្យង់ក៏បានមកទទួលការអប់រំជំនឿជាមួយលោកដែរ។ ក្នុងឆ្នាំ ២០០៦ មានបងស្រី ក្រុមដូមីនីកូ បានមកជួយនៅបឹងតាព្រហ្ម។បងស្រីសម្រាកនៅផ្ទះម្តាយក្មេករបស់លោកចាន់សារឿនដែរ គឺ២ថ្ងៃក្នុង មួយសប្តាហ៍រហូតដល់ព្រះវិហារបានសាងសង់រួច។ នៅឆ្នាំ២០០៧ លោកបូជាចារ្យវិរៈជ័យ បានធ្វើអគ្គសញ្ញាជ្រមុជទឹកជូនគ្រីស្តបរិស័ទម្នាក់។ ក្នុងឆ្នាំនោះដែរ លោកបានទិញដីមួយកន្លែង ដើម្បីធ្វើព្រះវិហារដោយបើកសម្ពោធនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៨។

មកដល់សព្វថ្ងៃនេះ ព្រះសហគមន៍បឹងតាព្រហ្ម មានគ្រីស្តបរិស័ទទាំងអស់៦នាក់ ប្រុស២នាក់និងជំហានទីមួយចំនួន១១នាក់ក្រុមកាយឫទ្ធិ៣០នាក់។ព្រះវិហារសន្តដូមីនីកូមានសកម្មភាពដូចជា ៖

- ការជួបជុំគ្នារៀងរាល់អាទិត្យ
- អប់រំជំនឿដល់យុវជន និងកុមារ
- អប់រំ យុវជន និងកុមារ អំពី តម្លៃនៃជីវិត
- ថ្នាក់មត្តេយ្យសិក្សា ។
- ការងារសង្គហៈ ៖ សួរសុខទុក្ខតាមផ្ទះ ជួយអ្នកជំងឺនិងអ្នកក្រីក្រ
- កម្មវិធីសុខភាព និង សកម្មភាពផ្សេងៗទៀត











សកម្មភាពរបស់លោកអភិបាលក្នុងដំណើរទស្សនកិច្ចនៅព្រះសហគមន៍បឹងតាព្រហ្ម

# ព្រះសហគមន៍កាតូលិក



## កោះខ្យង

- **ព្រះវិហារ៖** ព្រះវិហារព្រះនាងម៉ារី(កោះខ្យង)
- **ប្រធានក្រុមប្រឹក្សា៖** យុន យ៉ាក់
- **អប់រំជំនឿ៖** បងស្រី សាលវ៉ាស្យុង អ៊ីបារឡាសា
- **ទូរស័ព្ទទំនាក់ទំនង៖** ០១៥ ៧៩ ១៩ ៦៧

# ប្រវត្តិព្រះសហគមន៍ព្រះនាងម៉ារីកោះខ្យង

ប្រវត្តិព្រះសហគមន៍បានកកើតនៅកោះខ្យងនេះតាមរយៈនិកាយប្រូតេស្តង់លោកជិនជាក់បានទទួលពិធីជ្រមុជទឹកនៅថ្ងៃទី២៦ខែកញ្ញាឆ្នាំ១៩៩៨តាមរយៈគ្រូគង្វាល កាន់ឌីរិចដេវិត។ ក្រោយមកឆ្នាំ២០០១ ព្រះសហគមន៍កាតូលិកបានផ្សព្វផ្សាយព្រះបន្ទូលមកដល់កោះខ្យង តាមរយៈលោកតា ជិនម៉ៅ និង លោកតា ្វ៉ាន់ណៅ ហើយយើងទាំងអស់គ្នាជឿព្រមទាំងដើរតាមព្រះជាម្ចាស់។ លោកតា្វ៉ាន់ណៅ បានសុំច្បាប់អធិដ្ឋាននៅផ្ទះលោកកជិនជាក់។ ឆ្នាំ២០០៣ លោកវីរៈឆ័យ បានទិញដីនៅទីនេះ ដល់ឆ្នាំ២០០៤ថ្ងៃទី៣០ខែមិថុនា លោកបានសាងសង់ព្រះវិហារព្រះនាងម៉ារីនេះឡើង។ សកម្មភាពរបស់ព្រះសហគមន៍យើងខ្ញុំមានកម្មវិធីកាត់ដេរ សាលាមតេយ្យ ក្រុមរបាំ ក្រុមជួសជុលផ្ទះអោយអ្នកក្រីក្រ ជូនអ្នកជំងឺទៅមន្ទីរពេទ្យ ធ្វើអភិបូជាមួយអាទិត្យនៅកោះខ្យង និងមួយអាទិត្យនៅបឹងតាព្រហ្មសូត្រធម៌ផ្កាំថ្ងៃច័ន្ទនិងថ្ងៃ អង្គារដោយមានបងស្រីដឹងនាំ។ ព្រះសហគមន៍មានគណកម្មការ ២នាក់ គ្រូ២នាក់ និងគ្រីស្តបរិស័ទ៩គ្រួសារ មនុស្សចាស់១៦នាក់ កូនក្មេង១៤នាក់ កំពុងស្វែងយល់។





សកម្មភាពរបស់លោកអភិបាលក្នុងដំណើរទស្សនកិច្ចនៅព្រះសហគមន៍ព្រះនាងម៉ារីកោះខ្យង



សកម្មភាពរបស់លោកអភិបាលក្នុងដំណើរទស្សនកិច្ចនៅព្រះសហគមន៍ព្រះនាងម៉ារីកោះខ្យង





# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ ឝ្មីតហាស្មេរ ក្នុងឱកាសទស្សនកិច្ច មណ្ឌលសកម្មភាពកំពង់សោម ព្រះសហគមន៍កោះខ្យង ថ្ងៃទី ១៩ មិថុនា ២០១៥

បងប្អូនជាទីស្រឡាញ់!

នៅក្នុងអត្ថទី១ សន្តៈប៉ូលបានសង្ខេបពីជីវិតរបស់លោក ក្នុងឋានៈជាគ្រីស្តទូត ដែលរងទុក្ខលំបាកយ៉ាងខ្លាំង ដោយមានគេវាយដំលោកជាច្រើនដង គេចាប់លោកយកទៅឃុំឃាំងជាច្រើនដង លោកធ្វើដំណើរតាមផ្លូវទឹកជួបគ្រោះ ថ្នាក់លិចសំពៅចំនួន ៣ដង មានគេធ្វើបាបលោកជាច្រើនដងពេលលោកធ្វើដំណើរតាមផ្លូវគោក លោកជួបគ្រោះថ្នាក់នៅក្នុងក្រុង និងនៅក្នុងវាលរហោស្ថានដែរ... ពេលស្តាប់ហើយ យើងក៏អាចយល់ពីការលំបាករបស់លោក ប៉ុន្តែការ លំបាកដែលធ្ងន់ធ្ងរជាងជាប់ជាប់ឃុំឃាំងទៅទៀតនោះ គឺគេវាយលោកចំនួន ៣៩រំពាត់ ចំនួន ៥ដង ដោយសារតែ លោកជាសាវ័ករបស់ព្រះយេស៊ូ។

ដូច្នេះពេលស្តាប់អត្ថបទនេះហើយ តើយើងចង់ដើរតាមព្រះយេស៊ូឬអត់? តើយើងចង់ទៅជាសន្តៈប៉ូល ដែលត្រូវគេវាយត្រូវគេចាប់ ត្រូវគេមើលងាយ ត្រូវគេនិយាយអាក្រក់ដែរឬអត់?។ ចំពោះសន្តៈប៉ូលវិញ ទោះបីលោកជួបនឹងការលំបាកយ៉ាណាក៏ដោយ ក៏លោកនៅតែខ្វល់ខ្វាយនឹងព្រះសហគមន៍ជានិច្ចដោយលោកចុះ ទៅសួរសុខទុក្ខនិងលើកទឹកចិត្តដល់បងប្អូនគ្រីស្តបរិស័ទពីភូមិមួយទៅភូមិមួយ ពីទីក្រុងមួយទៅទីក្រុងមួយ ហើយលោកយកពេលនិយាយអំពីព្រះយេស៊ូឲ្យគេស្តាប់ និងលោកបង្កើតព្រះសហគមន៍តូចៗជាច្រើន។ខ្ញុំជឿថាយើងទាំងអស់គ្នាក៏ប្រព្រឹត្តដូចសន្តៈប៉ូលដែរគឺយើងបានទៅសួរសុខទុក្ខគ្នាលើកទឹកចិត្តគ្នាដល់ទីកន្លែងនីមួយៗ និងទោះបី យើងនៅមានគ្នាតិចពិតមែន ប៉ុន្តែយើងមានអំណរសប្បាយដោយសារយើងជាបងប្អូនគ្នាក្នុងអង្គព្រះគ្រីស្ត។

ថ្ងៃនេះព្រះយេស៊ូមានសំណួរមួយដ៏សំខាន់ដល់យើង ថាតើយើងទុកទ្រព្យសម្បត្តិរបស់យើងនៅឯណា? តើអ្វីទៅជាទ្រព្យសម្បត្តិរបស់យើង? ជាធម្មតាយើងឆ្លើយ ភ្លាមថា

លុយ គ្រឿងអលង្ការ ខ្សែដៃ ខ្សែកមាស ទូរស័ព្ទទំនើប ឡាន វីឡា...ដែលមាននៅក្នុងលោកីយ៍នេះជាទ្រព្យសម្បត្តិរបស់យើង។ ប៉ុន្តែទ្រព្យសម្បត្តិបែបនេះ ព្រះយេស៊ូមានព្រះបន្ទូលថា មិនអាចស្ថិតស្ថេរនិងគង់វង្សយូរអង្វែងបានទេ កណ្ដៀរនឹងស៊ី ច្រែះនឹងស៊ី បន្ទាប់មកវានឹងខូចអស់ទៅ។ ព្រះអង្គទូន្មានថា កុំឲ្យយើងទុកទ្រព្យសម្បត្តិនៅលើលោកីយ៍នេះ ប៉ុន្តែឲ្យយើងទុកទ្រព្យសម្បត្តិនៅស្ថានបរមសុខវិញ ដ្បិតទ្រព្យសម្បត្តិអ្នកនៅកន្លែងណា ចិត្តរបស់អ្នកក៏នៅកន្លែងនោះដែរ។ ពេលនេះចូរយើងគិតបន្តិច ថាតើអ្វីទៅជាទ្រព្យសម្បត្តិរបស់យើង? តាមធម្មតាក្នុងការរស់នៅ យើងត្រូវការលុយកាក់ ទ្រព្យសម្បត្តិតាមលោកីយ៍ ដើម្បីយើងមានបាយ ហូប ដើម្បីទៅសាលា ព្យាបាលជំងឺ ដើម្បីធ្វើដំណើរ... ប៉ុន្តែនេះមិនមែនជាអ្វីដែលសំខាន់បំផុតនោះទេ។ ព្រះយេស៊ូបានអញ្ជើញយើងឲ្យទៅជាគ្រីស្តបរិស័ទ ដោយឲ្យយើងលះបង់ចោលអ្វីៗទាំងអស់និងលីឈើឆ្កាងដើរតាមព្រះអង្គ។ សូមឲ្យយើងនឹកដល់ព្រះបន្ទូលនេះជានិច្ច តើអ្វីដែលជាទ្រព្យសម្បត្តិដ៏សំខាន់បំផុតរបស់យើង?។

ចំពោះយើងទ្រព្យសម្បត្តិដែលសំខាន់ជាងគេបំផុតនោះ គឺជាធម្មវិន័យដែលព្រះយេស៊ូប្រទានឲ្យយើង គឺព្រះអង្គសូមឲ្យយើង " ស្រឡាញ់គ្នាទៅវិញទៅមក ដូចព្រះអង្គបានស្រឡាញ់យើងដែរ "។ យើងត្រូវទុកធម្មវិន័យនេះជាទ្រព្យ សម្បត្តិពិសេសជាព្រះអំណោយទាន ដែលយើងត្រូវតែថែរក្សាទុកក្នុងចិត្តជានិច្ច និងពីមួយថ្ងៃទៅមួយថ្ងៃត្រូវពិចារណា ថាតើយើងត្រូវប្រព្រឹត្តធម្មវិន័យនេះតាមរបៀបណា? តើធ្វើដូចម្ដេចដើម្បីឲ្យយើងអនុវត្តនូវធម្មវិន័យនេះជាមួយក្មេងៗ ជាមួយអ្នកជំងឺ ជាមួយអ្នកក្រីក្រ ជាមួយយុវជនយុវនារី... ដើម្បីបង្ហាញថាធម្មវិន័យនេះ គឺជាទ្រព្យសម្បត្តិពិសេសរបស់យើងជាគ្រីស្តបរិស័ទ។ សេចក្តីស្រឡាញ់ គឺជារបៀបដែលយើងចាប់អារម្មណ៍ដល់អ្នកដទៃ ជារបៀបដែលយើងបង្កើតទំនាក់ទំនងជាមួយអ្នកដទៃ គឺយើងស្រឡាញ់ យើងលើកលែងទោស តាមរូបគំនូរជានិមិត្តរូបនៅលើប៉ាណូនៃឆ្នាំសម្តែង មេត្តាករុណា។ លើប៉ាណូនេះមានរូបពីរ ទីមួយគឺព្រះយេស៊ូលាងជើងឲ្យក្រុមគ្រីស្តទូត និងទីពីរគឺបុរសជនជាតិសាម៉ារី ម្នាក់ធ្វើដំណើរតាមផ្លូវជួបអ្នកដែលមានរបួស ហើយគាត់សុខចិត្តលាងរបួសឲ្យគេ ដើម្បីបង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ដល់អ្នករបួសនេះ ជាទ្រព្យសម្បត្តិដែលយើងបានទទួល។ សូមឲ្យយើងចងចាំប្រសាសន៍សន្តៈប៉ូលដែលថា " ខ្ញុំបានបម្រើបងប្អូនអស់មួយជីវិត "។ ចំពោះយើងក៏ត្រូវតែជាអ្នកបម្រើដូចសន្តៈប៉ូលដែរ ប៉ុន្តែតាមរបៀបរបស់យើងម្នាក់ៗ ដែលជាមនុស្សចាស់

ឬជាក្មេងៗ។ យើងក្មេងៗត្រូវទៅជាអ្នកបម្រើដោយបម្រើឪពុកម្តាយ បម្រើបងប្អូនឯទៀតៗ បម្រើអ្នកតូចតាច ជួយបង្រៀនអ្នកដែលមិនបានចូលសាលារៀន បម្រើកូនកាយរិទ្ធបម្រើអ្នកជំងឺ...។ យើងទុករបៀប បម្រើទាំងអស់នេះជាទ្រព្យសម្បត្តិពិសេស ក្នុងការដឹកនាំជីវិតរបស់យើង ដែលបន្តិចម្តងៗធ្វើឲ្យព្រះសហាគមន៍ របស់យើងទៅជាពន្លឺមួយ។ នៅទីនេះពិសេសណាស់ ដោយសារព្រះសហាមន៍របស់យើងនៅលើភ្នំ យើងខ្ពស់ជាងគេ តែមិនមែនខ្ពស់ជាងគេដោយសារយើងល្អជាងគេ ប៉ុន្តែដោយសារពន្លឺរបស់ព្រះជាម្ចាស់បានបំភ្លឺដល់គេ។ ព្រះយេស៊ូមានព្រះ បន្ទូលថា " ចូរប្រយ័ត្នប្រសិនបើពន្លឺនៅក្នុងអ្នកត្រឡប់ ទៅជាងងឹតទៅហើយនោះ មិនដឹងជាសេចក្តីងងឹតនឹងទៅជាសូន្យសុងដល់កម្រិតណាទៀតទេ " ដូច្នេះត្រូវឲ្យពន្លឺរបស់យើងភ្លឺទាំងយប់ទាំងថ្ងៃ ដើម្បីឲ្យគេដឹងថាកន្លែងនេះជាកន្លែងនៃធម៌មេត្តាករុណា កន្លែងនេះជាកន្លែងមានបងប្អូនដែលរង់ចាំស្វាគមន៍ ជាកន្លែងមួយពិសេសសម្រាប់អ្នកអត់ទីពឹង អ្នកដែលអត់មានសេចក្តីសង្ឃឹម អ្នកដែលអត់ដឹងទៅទីណា...។

ដូច្នេះចូរបើកទ្វារកន្លែងរបស់យើងគ្រប់ពេលវេលារង់ចាំ ទទួលបងប្អូនតួនាទីរបស់យើងធ្ងន់ណាស់ ដោយសារយើងត្រូវតែទទួលស្វាគមន៍អ្នកដែលគ្មានទីដៅគ្រប់ពេលវេលា ហើយយើងក៏ត្រូវរកពេលដើម្បីរិះគិតពីជីវិតរបស់យើងជាគ្រីស្តបរិស័ទដែរ។ ព្រះយេស៊ូបានបង្រៀនយើង ឲ្យយើងចេះជួយគ្នាទៅវិញទៅមកដោយដឹងថា យើងទីពឹងលើព្រះយេស៊ូទីពឹងលើព្រះបន្ទូល និងយើងទីពឹងលើព្រះសហាគមន៍។

ដូច្នេះចូរឲ្យយើងជួយគ្នាទៅវិញទៅមកដើម្បីកសាងព្រះសហាមគន៍របស់យើង មិនមែនទីពឹងតែលើលោកឪពុក បងស្រីតែប៉ុណ្ណឹង ឬតែលើគណៈកម្មការ ប៉ុន្តែគឺយើងទាំងអស់គ្នាទីពឹងលើគ្នាទៅវិញទៅមក ជួយគ្នាទៅវិញទៅមកដើម្បីបង្កើតក្រុមគ្រួសាររបស់ព្រះយេស៊ូ។ ចូរយើងនៅស្ងៀមស្ងាត់ដើម្បីអរព្រះគុណព្រះបិតា ដែលបានប្រទានទ្រព្យសម្បត្តិមួយយ៉ាងពិសេស គឺសេចក្តីស្រឡាញ់របស់ព្រះអង្គតាមរយៈព្រះគ្រីស្តឲ្យយើងទុកទ្រព្យសម្បត្តិដ៏ពិសេសនៅក្នុង ដួងចិត្តរបស់យើង ដើម្បីយើងរស់នៅតាមរបៀបព្រះយេស៊ូដែលបានបង្រៀនយើង។ អាម៉ែន។

# ក្រុមបងស្រីដូមីនីក











- **អាស័យដ្ឋាន ៖** ផ្លូវ១២-១៣ សង្កាត់៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ
- **អ៊ីម៉ែល ៖** ssiop@yahoo.com ប្រអប់សំបុត្រ៖ ១២៣ ភ្នំពេញ
- **អប់រំជំនឿ ៖** បងស្រី សាលវ៉ាស្យុង អ៊ីបារឡាសា
- **ទូរស័ព្ទទំនាក់ទំនង ៖** ០១៥ ៧៩ ១៩ ៦៧



សកម្មភាពរបស់លោកអភិបាលនៅភូមិពុងភា ដែលជាភូមិក្រីក្រមួយ ព្រះសហគមន៍កំពង់សោម
បានសាងសង់សាលារៀនមួយ តាមរយៈក្រុមបងស្រីដូមីនីក









មណ្ឌលជលធាជីវិតរបស់ក្រុមបងស្រីគង្វាលដ៏សប្បុរស

# ក្រុមបងស្រីគង្វាលដ៏សប្បុរស







សកម្មភាពរបស់លោកអភិបាលក្នុងដំណើរទស្សនកិច្ចនៅក្រុមគ្រួសារគង្វាលដ៏សប្បុរស













# សាលាបច្ចេកទេសដុនបូស្កូ













និស្សិតសាលាដុនបូស្កូសំអាតបរិស្ថាន

# ព្រះសហគមន៍កាតូលិក

## សន្តមីកាអែល (ព្រះសីហនុ)

- **ព្រះវិហារ ៖** ព្រះវិហារសន្តមីកាអែល (ព្រះសីហនុ)
- **អាសយដ្ឋាន ៖** ព្រះវិហារកាតូលិកផ្លូវ C.T
- **ប្រធានក្រុមប្រឹក្សា ៖** នូ ចាន់សារឿន
- **អបរំជំនឿ ៖** បងស្រី អ៊ីប៉ាដូឡាហ្សា សាលវ៉ាស្សុន
- **ទូរស័ព្ទទំនាក់ទំនង ៖** ០១៥ ៧៩ ១៩ ៦៧



# ប្រវត្តិព្រះសហគមន៍សន្តមីកាអែល
# ឆ្នាំ ១៩៦៥-២០១៥

ឆ្នាំ១៩៥៧ មានគ្រីស្តបរិស័ទបារាំងនិងវៀតណាម មួយចំនួនតូច មកនៅក្នុងក្រុងព្រះសីហនុ ដូច្នេះលោកអភិបាល ហ្គូស្តាវ៉ូ វ៉ាបាឡាំង បានចាត់លោកបូជាចារ្យ អ៊ីវ វ៉ាមូស ឲ្យថ្វាយអភិបូជាបុណ្យចម្លងជាមួយគ្រីស្តបរិស័ទនៅទីនោះ។

នៅពេលលោកអភិបាល ហ្គូស្តាវ៉ូ វ៉ាបាឡាំង វិលត្រឡប់ទៅប្រទេសបារាំងវិញ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៦៣ លោកបូជាចារ្យ អ៊ីវ វ៉ាមូស បានបន្តតួនាទីមើលថែរ ក្នុងនាមលោកអភិបាល វ៉ាបាឡាំង នៅក្រុងភ្នំពេញ។ ក្រោយមក លោកបូជាចារ្យ អ៊ីវ វ៉ាមូស បានទទួលអគ្គសញ្ញាតែងតាំងជាលោកអភិបាលនៃភូមិភាគភ្នំពេញ ។

- ឆ្នាំ១៩៦៣ លោកអភិបាល អ៊ីវ វ៉ាមូស បានផ្ញើលិខិតមួយច្បាប់ថ្វាយសម្តេចព្រះនរោត្តម សីហនុ ដោយស្នើសុំឲ្យប្រទានដីមួយប្លង់នៅក្រុងព្រះសីហនុ សម្រាប់ព្រះសហគមន៍កាតូលិក។

- ក្នុងឆ្នាំ១៩៦៤ សម្តេចព្រះនរោត្តម សីហនុបានព្រះរាជប្រទាន ដីមួយប្លង់ជាផ្លូវការដល់ព្រះសហគមន៍កាតូលិក។ នៅឆ្នាំដដែលនោះលោកអភិបាល អ៊ីវ វ៉ាមូស ជាមួយលោកឪពុក Ahadoberry ជាបូជាចារ្យជាតិបាស្កេ ដោយមានការឧបត្ថមពីសំណាក់លោក វ៉ាន់ ម៉ូលីវ៉ាន់ ជាស្ថាបត្យករខ្មែរ ចាប់ផ្តើមសាងសង់ព្រះវិហារ។

ក្នុងឆ្នាំ១៩៦៥ ព្រះវិហារកាតូលិកនៅក្រុងព្រះសីហនុត្រូវបានកសាងឡើងរួចរាល់។ ពេលនោះពុំមានបូជាចារ្យដើម្បីណែនាំថែរក្សា ក្រុមគ្រួសារកាតូលិក ៣ ឬ ៤ គ្រួសារនៅទីនោះទេ។

នៅសម័យលោកសេនាប្រមុខ លន់ នល់ ក្នុងឆ្នាំ១៩៧០-១៩៧៥ អ្នករស់នៅក្រុងព្រះសីហនុ មានចំនួនកើនឡើង គ្រីស្តបរិស័ទបានកើនឡើង រហូតចំនួន២០គ្រួសារ។

របបខ្មែរក្រហមនៅឆ្នាំ១៩៧៥-១៩៧៩ ហើយរហូតដល់ឆ្នាំ១៩៩០ គេបានយកព្រះវិហារនេះធ្វើជាពន្ធនាគារ និងក្រោលសត្វ ហើយមួយផ្នែកជាបន្ទប់ដាក់ឥវ៉ាន់ ដែលជាមូលហេតុនាំឲ្យព្រះវិហារនេះរួចផុតពីការបំផ្លាញ។

ក្នុងឆ្នាំ១៩៩១ ព្រះវិហារនេះបានក្លាយទៅជាទីស្នាក់ការទី៦ របស់ទាហានអ៊ុនតាក់ (អាជ្ញាធរបណ្ដោះអសន្ន នៃអង្គការសហប្រជាជាតិក្នុងប្រទេសកម្ពុជា)។ ក្នុងចំណោមទាហានទាំងនេះមានខ្លះជាគ្រីស្តបរិស័ទកាតូលិក បានទទួលការអនុញ្ញាតឲ្យមានបូជាចារ្យទៅថ្វាយអភិបូជាជាមួយពួកគេ។

ទាហានជាកាតូលិកមានជំនឿលើឫទ្ធានុភាពនៃសន្តទេវទូតមីកាអែល ជាអ្នកការពារពួកគេ ហើយបានគូររូបសន្តទេវទូតមីកាអែលដាក់ពីមុខព្រះវិហារ។ ចាប់តាំងពីពេលនោះព្រះវិហារកាតូលិកនៅក្នុងក្រុងព្រះសីហនុបានចាប់បដិសន្ធិមានឈ្មោះថាព្រះវិហារសន្តមីកាអែល។ បានជាកម្មសិទ្ធិរបស់ព្រះសហគមន៍នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៣។

នៅចុងឆ្នាំ១៩៩៣ ខណៈ ដែលក្រុមគ្រួសារគ្រីស្តបរិស័ទកំពុងមានចំនួនកើនឡើង លោកអភិបាល អ៊ីវ រ៉ាមូស បានស្នើសុំលោកបូជាចារ្យ វិនណេ ឲ្យជួយថែរក្សាព្រះសហគមន៍នោះ។

ចាប់ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០០១ លោកបូជាចារ្យ វិនរណេ បានទៅជួបគ្រីស្តបរិស័ទនៅពាសពេញខេត្តព្រះសីហនុ ឆ្ងាយរហូតដល់កោះកុង កោះស្ដេច និងស្រែអំបិល។ គាត់បានបើកមណ្ឌលមួយសម្រាប់អ្នកក្រីក្រ និងអ្នកដែលរស់នៅក្នុងភូមិដាច់ស្រយាល។

ក្នុងឆ្នាំ២០០០ មុនពេលលោកបូជាចារ្យ វិនណេ ផ្លាស់មកកាន់ទីក្រុងភ្នំពេញ លោកបានផ្ដួចផ្ដើមកសាងផ្ទះសម្រាប់សំណាក់ធម៌នៅព្រះវិហារសន្តមីកាអែល។

ក្នុងឆ្នាំ២០០១ សាសនទូតថៃ គឺលោកបូជាចារ្យ វីរៈជ័យ ស្រ៊ីប្រាម៉ង បានមកជួយលោកឪពុក វិនណេ នៅក្នុងមុខងារបម្រើរបស់គាត់។ ក្រោយមកលោកឪពុក វីរៈជ័យ បានទទួលខុសត្រូវទាំងស្រុង បន្តពីលោកឪពុក វិនណេ។

ចាប់ពីឆ្នាំ២០០១ ដល់ឆ្នាំ២០១១ លោកបូជាចារ្យ វីរៈជ័យ បានទៅជួបប្រាស្រ័យទាក់ទងជាមួយគ្រីស្តបរិស័ទកាន់តែច្រើនឡើងៗ ហើយបានកសាងព្រះវិហារតូចៗ នៅភូមិកោះខ្យង បឹងតាព្រហ្ម និងត្រែងត្រយឹង ដើម្បីឲ្យគ្រីស្តបរិស័ទជួបជុំគ្នាអធិដ្ឋានរាល់ថ្ងៃអាទិត្យ។ លោកបូជាចារ្យឲ្យមកជួយលោកឪពុក វីរៈជ័យ នៅក្នុងកិច្ចការមប្រើព្រះសហគមន៍ក្នុងតំបន់នេះ មានដូចជាគឺ៖

- ឆ្នាំ ២០០២-២០០៣ លោកបូជាចារ្យ Arokiadoss ក្រុមMEP
- ឆ្នាំ ២០០៤-២០០៦លោកបូជាចារ្យ ផ៉ត្រ សិរី ក្រុម TMS

- ឆ្នាំ២០០៦-២០០៨ លោកបូជាចារ្យ Christophe ក្រុមMEP
- ឆ្នាំ២០០៩-២០១២ លោកបូជាចារ្យ Denis Carier ( ទទួលមរណភាព )។

ក្នុងឆ្នាំ២០០៥ តាមការអញ្ជើញពីសំណាក់លោកអភិបាល អេមីល ដេតម្ប ក៏មានក្រុមគ្រួសារបងស្រីសន្តដូមីនិក បានមកជួយនៅក្នុងកិច្ចការទាំងអស់ តាមការចាត់ចែងរបស់ព្រះសហគមន៍។

ដោយជាការជួយពីសំណាក់ក្រុមបងស្រី ថ្នាក់មត្តេយ្យនៅភូមិកោះខ្សុង ថ្នាក់នៅបឹងតាព្រហ្ម និងត្រែងត្រយឹង ក៏ត្រូវបានបើក។ មួយឆ្នាំក្រោយមក បើកកម្មវិធីអក្ខរកម្ម នៅ ភូមិពុង ៣ និងភូមិរមាសងាប់ សម្រាប់កុមារពុំបានរៀនសូត្រ។ បន្ថែមពីនេះទៀត កម្មវិធីអប់រំ និងបំប៉ន បានពង្រីកឲ្យ ដល់យុវជន និងកុមារស្របពេលដែលកម្មវិធីបង្រៀនកាត់ដេរ និងធ្វើម្ហូប ត្រូវបានផ្តល់សម្រាប់ស្ត្រីនៅ ស្រែអំបិល ភូមិកោះខ្សុង បឹងតាព្រហ្ម និងត្រែងត្រយឹង។

ក្នុងឆ្នាំ២០១២ លោកឪពុក អ៊ុន សុន ជាលោកបូជាចារ្យខ្មែរ ត្រូវបានលោកអភិបាល អូលីវីយេ ចាត់ឲ្យមកទទួលខុសត្រូវនៅព្រះសហគមន៍សន្តមីកាអែល។ ប្រាំមួយខែ ក្រោយមក លោកឪពុកដេនីស បានទទួលមរណភាពនៅថ្ងៃទី ១៩ ខែធ្នូឆ្នាំ២០១៣ ក៏មានលោកបូជាចារ្យ ដាមីញ៉ាំង (Damien, MEP) បានមកជួយព្រះសហគមន៍នោះ។









សកម្មភាពរបស់លោកអភិបាលនៅក្នុងដំណើរទស្សកិច្ចនៅកំពង់សោម





# ធម្មទេសនារបស់លោកអភិបាលអូលីវីយេស្មីតហាស្លែរ
# ក្នុងឱកាសទស្សនកិច្ច
# មណ្ឌលសកម្មភាពកំពង់សោម
# ព្រះសហគមន៍កំពង់សោម ថ្ងៃទី ២១ មិថុនា ២០១៥

បងប្អូនជាទីស្រឡាញ់!

អត្ថបទថ្ងៃនេះ បានថែងថា " រំពេចនោះមានព្យុះសន្ទឹកពីលើមេឃដូចខ្យល់បក់បោកយ៉ាងខ្លាំង " ខ្ញុំសង្ឃឹមថាថ្ងៃនេះ ព្រះវិញ្ញាណដ៏វិសុទ្ធដែលយាងមកកាល ២.000 ឆ្នាំមុន នៅចំពោះមុខក្រុមគ្រីស្តទូត ក៏នឹងយាងមកនៅចំពោះ មុខយើងពេលនេះដែរ។ ថ្ងៃនេះព្រះយេស៊ូបានខិតខំបង្រៀនមហាជនពេញមួយថ្ងៃ ក្រុមគ្រីស្តទូត ដែលដើរតាមព្រះអង្គក៏អស់កម្លាំងនិងចង់សម្រាក ប៉ុន្តែព្រះយេស៊ូមានព្រះបន្ទូលទៅគេថា " ចូរយើងនាំគ្នាឆ្លង ទៅត្រើយម្ខាង " ពេលនោះ ក្រុមគ្រីស្តទូតក៏ចាកចេញពីបណ្តាជនហើយអុំទូកចេញទៅ ដែលមានព្រះយេស៊ូគង់នៅក្នុងទូកនោះ។ ពេលយើងស្តាប់ ឮថាព្រះយេស៊ូគង់នៅក្នុងទូកជាមួយក្រុមគ្រីស្តទូក នាំឲ្យយើងនឹកឃើញដល់ព្រះសហគមន៍ដែលមានព្រះយេស៊ូគង់ នៅជាមួយ។ ព្រះសហគមន៍របស់យើងប្រៀបដូចជាទូកមួយ ដែលកំពុងធ្វើដំណើរលើសមុទ្រ។

ពេលនឹកឃើញកន្លែងនីមួយៗនៅក្នុងមណ្ឌលសកម្មភាពកំពង់សោម ដែលខ្ញុំបានទៅដល់ក្នុងមួយអាទិត្យនេះ ខ្ញុំមានអារម្មណ៍ថា ព្រះសហគមន៍ទាំងនោះប្រៀបដូចជាទូកមួយយ៉ាងតូចដែលខិតខំរស់នៅគ្រប់ពេលវេលា ដែលពេលខ្លះជួបអាកាសធាតុល្អ មានពន្លឺព្រះអាទិត្យរលកស្ងប់ ពេលខ្លះអាកាសធាតុមិនល្អ មានរលកយ៉ាងធំ មានខ្យល់បក់ជួនកាលយើងអរសប្បាយជួនកាលយើងភ័យ។ នេះជារបៀបដែលយើងធ្វើដំណើរជាមួយព្រះយេស៊ូ ប៉ុន្តែយើងដឹងថា នៅក្នុងទូករបស់យើង គឺក្នុងព្រះសហគមន៍មានព្រះយេស៊ូគង់នៅជាមួយគ្រប់ពេលវេលា ជាពិសេសពេលមានទុក្ខលំបាក ព្រះអង្គលើកទឹកចិត្តយើងដូចព្រះអង្គលើកទឹកចិត្តក្រុមគ្រីស្តទូតពេលគេភ័យដោយសារមានខ្យល់បក់ខ្លាំង។

នៅក្នុង ជីវិតរបស់យើង នៅក្នុងព្រះសហគមន៍របស់យើង ជួនកាលយើងក៏ភ័យដែរដោយសារគិតថា យើងឥតមានសមត្ថភាពយើងឥតមានកម្លាំងល្មម ប៉ុន្តែយើងដឹងថាព្រះយេស៊ូគង់នៅជាមួយយើង និងមានព្រះបន្ទូលថា " កុំខ្លាចអី! ខ្ញុំនៅជាមួយ "។ អត្ថបទព្រះ

គម្ពីថ្ងៃនេះរំឭកថា សព្វថ្ងៃយើងនៅក្នុងទូកមួយដែលមានព្រះយេស៊ូកំពុងផ្ទំលក់ តែនៅពេលយើងជួបបញ្ហា នោះព្រះអង្គនឹងតើនឡើងភ្លាម ដើម្បីលើកទឹកចិត្តយើងឲ្យបន្តដំណើរទៅមុខទៀត។ ដូច្នេះ ជីវិតរបស់យើង និងជីវិតរបស់ព្រះសហគមន៍ ប្រៀបបីដូចទូកមួយដែលកំពុងធ្វើដំណើរក្នុងអាកាសធាតុល្អផង និងអាក្រក់ផង ក៏ប៉ុន្តែ យើងមានព្រះយេស៊ូគង់នៅជាមួយ។

ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ចំពោះព្រះសហគមន៍ទាំងអស់ ដែលខ្ញុំបានទៅឃើញគឺជាព្រះសហគមន៍តូចៗ ប៉ុន្តែជាព្រះសហគមន៍ដែលមានជីវិតមានការរីកចម្រើន ដូចជាព្រះសហគមន៍ស្រែអំបិលកំពុងតែកសាងមណ្ឌលថ្មីមួយ ហើយបងប្អូនខិតខំរស់នៅជាមួយគ្នាជាផ្លុងមួយ។ ជាពិសេសទៅទៀត ព្រះសហគមន៍នីមួយៗខិតខំធ្វើជាពន្លឺតូចមួយ នៅកន្លែងដែលខ្លួនរស់នៅ ដូចជានៅផ្សារកោះកុង ផ្សារស្រែអំបិលជាដើម ដើម្បីឲ្យគេដឹងថាកន្លែងរបស់យើងមានព្រះ យេស៊ូគង់នៅជាមួយ ជាកន្លែងដែលមានសេចក្ដីសុខ។

ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ សម្រាប់លោកឪពុក សម្រាប់ បងស្រី សម្រាប់អស់បងប្អូនដែលបម្រើព្រះសហគមន៍ដោយយកចិត្តទុកដាក់អស់ពីសមត្ថភាពធ្វើជាគង្វាលណែនាំព្រះសហគមន៍អស់ពីកម្លាំងកាយចិត្ត ដោយសេចក្ដីស្រឡាញ់ដែលមកពីព្រះយេស៊ូ។ សូមអរព្រះគុណព្រះជាម្ចាស់ សម្រាប់បងប្អូនម្នាក់ៗជាតំណាងអញ្ជើញមកពីព្រះសហគមន៍នានាយើងទាំងអស់គ្នាជាព្រះសហគមន៍ដែលមាន អំណរសប្បាយ។ ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ សម្រាប់បងប្អូនទាំងអស់ ដែលរស់នៅដោយស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដើម្បីកសាងព្រះសហគមន៍របស់យើង។

ក្នុងអត្ថបទទីពីរ សន្ដៈប៉ូលមានប្រសាសន៍ថា ៖ ព្រះអង្គសោយទិវង្គតសម្រាប់មនុស្សទាំងអស់ដើម្បីឲ្យអស់អ្នកដែលមានជីវិត លែងរស់នៅសម្រាប់ខ្លួនឯងទៀតហើយ គឺរស់នៅសម្រាប់ព្រះអង្គ ដែលបានសោយទិវង្គតនិង មានព្រះជន្មរស់ឡើងវិញ។ ព្រះយេស៊ូសោយបានទិវង្គតដើម្បីឲ្យយើងមានជីវិតថ្មី ជាជីវិតដែលមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន ជាជីវិតដែលសម្លឹងមើលព្រះយេស៊ូ ដើម្បីឲ្យយើងទៅជាសាវ័ករបស់ព្រះអង្គ និងឲ្យព្រះយេស៊ូយាងចូលនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើងជាអាទិភាពនៃជីវិតរបស់យើង។ ដូច្នេះសូមឲ្យយើងខិតខំលះបង់ចោលជីវិតចាស់ ដើម្បីបង្កើតជីវិតថ្មីរួមជាមួយបងប្អូនជាពិសេស គឺសម្រាប់បងប្អូន ដែលនឹងទទួលអគ្គសញ្ញាលាបថ្ងាសនៅពេលបន្តិចទៀតនេះ ដែលចង់ក្លាយទៅ

ជាគ្រីស្តបរិស័ទយ៉ាងពិតប្រាកដ ដែលដើរតាមព្រះយេស៊ូ។ ពេលនេះ ខ្ញុំមានបីចំណុចសំខាន់ដើម្បីឲ្យព្រះសហគមន៍របស់យើងបន្តរីកចម្រើន និងបន្តកសាង ព្រះរាជ្យរបស់ព្រះជាម្ចាស់៖

ទី១ សូមឲ្យបងប្អូនបន្តថែរក្សាក្រុមគ្រីស្តបរិស័ទរបស់យើងតទៅទៀត ទោះបីយើងតូចមានគ្នាតិចប៉ុន្តែសំខាន់គឺឲ្យយើងថែរក្សា។ យើងទាំងអស់គ្នាជាព្រះសហគមន៍ យើងម្នាក់ៗត្រូវថែរក្សាគ្នាទៅវិញទៅមក ដោយយកចិត្តទុកដាក់ណែនាំឲ្យបងប្អូនមានឱកាស ដើម្បីអធិដ្ឋាន ដើម្បីភ្ជាប់ជាមួយព្រះយេស៊ូតាមរយៈការអធិដ្ឋាន ទោះបីគ្មានបូជាចារ្យគ្មានបងប្រុស បងស្រីមកជារៀងរាល់ថ្ងៃក៏ដោយ។ នេះជារបៀបដើម្បីថែរក្សាជីវិតរបស់យើងជាគ្រីស្តបរិស័ទ។ មួយទៀតថែរក្សាដោយយកចិត្តទុកដាក់អប់រំជំនឿ គឺយើងអប់រំក្រុមក្មេងៗមានក្រុមអ្នកទទួលព្រះកាយ មានក្រុមអ្នក ទទួលអគ្គសញ្ញាលាបថ្ងាសជាដើម។ យើងជាគ្រីស្តបរិស័ទ ពេលទទួលអគ្គសញ្ញាអស់ហើយ កុំគិតថាការអប់រំជំនឿ របស់យើងចប់មិនមែនដូច្នោះទេ គឺយើងត្រូវអប់រំជំនឿអស់មួយជីវិត តាមរយៈសំណាក់ធម៌យូរៗម្តង តាមរយៈការអានព្រះគម្ពីររួមគ្នា... ដូច្នេះត្រូវបង្កើតបរិយាកាសឲ្យគ្រីស្តបរិស័ទជួបជុំគ្នា រិះគិតថែមទៀតពីជីវិតជាគ្រីស្តបរិស័ទមានអត្ថន័យយ៉ាងណា ? តើព្រះបន្ទូលថ្ងៃនេះមានអត្ថន័យយ៉ាងណាសម្រាប់ជីវិតរបស់ខ្ញុំ ?។ យើងត្រូវជួយគ្នាទៅវិញទៅមក ព្រោះយើងមានកម្លាំងមានសមត្ថភាពផ្សេងៗគ្នា។ តាមកន្លែងនីមួយៗ សូមអញ្ជើញចាស់ៗមកសហការជាមួយក្មេងៗ និងឲ្យក្មេងៗសហការជាមួយចាស់ៗទៅវិញទៅមក។ សូមឲ្យយុវជនយុវនារី ចេះសហការគ្នាជាមួយមនុស្សពេញវ័យ ជាមួយចាស់ៗ ដើម្បីជួយគ្នាទៅវិញទៅមកក្នុងការកសាងព្រះសហគមន៍។ សូមឲ្យយើងយកចិត្តទុកដាក់នឹងក្រុមគ្រួសារ ដោយជួយអប់រំក្រុមគ្រួសារតាមរបៀបព្រះសហគមន៍ ដោយសារក្រុមគ្រួសារជាព្រះសហគមន៍តូចមួយជា កោសិកានៃព្រះសហគមន៍។ ពេលអប់រំអំពីរឿងគ្រួសារ ត្រូវអប់រំពីដំណាក់កាលទាំងបីគឺមុនពេលរៀបការ នៅពេលរៀបការ និងនៅក្រោយពេលរៀបការ ដើម្បីឲ្យក្រុមគ្រួសារនីមួយៗរីកចម្រើននៅក្នុងជំនឿ អាចរួមគ្នាជាមហាគ្រួសារដ៏ប្រសើររបស់ព្រះជាម្ចាស់ជាគោលនៃព្រះសហគមន៍របស់យើង។

ទី២ ចូរឲ្យយើងនឹកឃើញដល់បងប្អូនដែលជាគ្រីស្តបរិស័ទហើយ តែឃ្លាតឆ្ងាយពីព្រះសហគមន៍។ ព្រះយេស៊ូមានប្រស្នាអំពីគង្វាលដែលមើលថែចៀម ១០០ក្បាល ហើយមាន ១ក្បាលវង្វេងចេញពីហ្វូង។ ពេលនោះគង្វាលដ៏ សប្បុរសបានទុកចៀម ៩៩ក្បាល

ចោល ដើម្បីទៅស្វែងរកចៀម ១ក្បាល ដែលបាត់។ ដូច្នេះ តើយើងធ្វើដូចម្តេចដើម្បីរកឃើញបងប្អូនយើងដែលសព្វថ្ងៃមិនសូវរវីរវល់នឹងជំនឿ? ជួនកាលនៅក្នុងក្រុមគ្រួសាររបស់យើងផ្ទាល់មានកូនចៅរបស់យើងខ្លះក៏មិនបានទទួលការអប់រំជំនឿដែរ។ តើធ្វើដូចម្តេចដើម្បីឲ្យកូនចៅរបស់គ្រីស្តបរិស័ទយើងបានមកទទួលការអប់រំជំនឿ? តើធ្វើដូចម្តេចដើម្បីឲ្យគេមានអំណរសប្បាយដូចយើងដែលមានអំណរសប្បាយ ដោយបានទទួលព្រះកាយព្រះគ្រីស្ត?។ ចូរយកចិត្តទុកដាក់ថែមទៀត ដោយទៅសួរសុខទុក្ខបងប្អូនយើងដែលឃ្លាតឆ្ងាយពីព្រះសហគមន៍។ ជាការប្រសើរ ប្រសិនបើមានក្រុមយុវជនយុវនារីរួមជាមួយក្រុមចាស់ៗទៅសួរសុខទុក្ខគ្រីស្តបរិស័ទ ដែលពីយូរឆ្នាំហើយ មិនបានចូលព្រះវិហារសោះ។ នេះជាតួនាទីរបស់យើង ដូច្នេះយើងត្រូវមានចិត្តអត់ធ្មត់ ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យយើងមានចិត្តអត់ធ្មត់ ដើម្បីធ្វើដំណើរបន្តិចម្តងៗក្នុងការអប់រំបងប្អូនទាំងនោះឲ្យយល់អំពីសារៈសំខាន់ នៃជីវិតរួមជាមួយព្រះយេស៊ូ។

ទី៣ តើយើងធ្វើដូចម្តេចដើម្បីប្រកាសដំណឹងល្អដល់បងប្អូនឯទៀតៗ ដែលមិនទាន់ស្គាល់ព្រះយេស៊ូ? នេះជា តួនាទីពិសេសដែលយើងបានទទួលពីព្រះយេស៊ូ។ មុនយាងឡើងស្ថានបរមសុខ ព្រះយេស៊ូមានព្រះបន្ទូលតែមួយគត់ ដល់ក្រុមគ្រីស្តទូតទុកជាមរតកគឺ " សូមទៅទូទាំងពិភពលោកទាំងមូល ដល់ទីដាច់ស្រយាលនៃផែនដីដើម្បីប្រកាសដំណឹងល្អ ធ្វើពិធីជ្រមុជទឹកឲ្យគេដោយព្រះនាមព្រះបិតា ព្រះបុត្រានិងព្រះវិញ្ញាណដ៏វិសុទ្ធ សូមព្យាបាលអ្នកជំងឺ និងខ្ញុំគង់នៅជាមួយអ្នករាល់គ្នាអស់កាលជានិច្ច"នេះជាតួនាទីរបស់យើងជាអត្តសញ្ញាណរបស់យើងជាជីវិតរបស់យើងជាសាសនទូត។ទូតមានន័យថាជាអ្នកប្រាប់ដំណឹង ដូច្នេះយើងជាទូតនៃសាសនាជាទូតរបស់ព្រះយេស៊ូ ជាអ្នកប្រាប់ដំណឹងអំពីព្រះយេស៊ូ។

ព្រះសហគមន៍របស់យើងមានបើកសាលាមត្តេយ្យ មានកម្មវិធីកាត់ដេរ ដូច្នេះយើងត្រូវបើកទ្វាចំហដើម្បីទទួលបងប្អូនឯទៀតៗ។ នៅទីនេះយើងមានសកម្មភាពជាច្រើនជាមួយអ្នកជំងឺ នេះជារបៀបប្រកាសដំណឹងល្អ តាមរបៀបដែលយើងសម្តែងមេត្តាករុណា។ យើងមិនប្រកាសដំណឹងល្អតាមតែបបូរមាត់ តែតាមការជាក់ស្តែង តាមរយៈការសម្តែងមេត្តាករុណាដែលយើងបានធ្វើ។ ឧទាហរណ៍ យើងមានកម្មវិធីកាយរិទ្ធិ ជាមួយក្មេងៗណែនាំឲ្យក្មេងៗ ហៅគ្នាគេមកថែមទៀត គេលែងប្រកាន់សាសនាហើយ តែគេសប្បាយ

ចិត្តជាមួយគ្នាដោយសារយើងមានកម្មវិធីសម្រាប់គេ។ ថ្ងៃនេះខ្ញុំសូមរំឭកបងប្អូនថា យើងមិនមែនតែជាអ្នកដែលប្រកាសដំណឹងល្អរួមគ្នា តែយើងក៏ប្រកាស ដំណឹងល្អរៀងៗខ្លួនដែរ ដោយសួរខ្លួនឯងថា " តើថ្ងៃនេះខ្ញុំបានធ្វើអ្វីដែលល្អសម្រាប់អ្នកដទៃ?" " តើខ្ញុំបានបង្ហាញសេចក្តីស្រឡាញ់អ្វីខ្លះដល់អ្នកដែលខ្ញុំបានជួប?" ព្រះយេស៊ូណែនាំឲ្យយើងមើលព្រះអង្គដោយនឹកឃើញដល់បងប្អូនឯទៀតៗ។ ព្រះយេស៊ូមានព្រះបន្ទូលថា " កុំខ្លាចអី! ខ្ញុំគង់ជាមួយអ្នករាល់គ្នា" ថ្ងៃនេះព្រះវិញ្ញាណដ៏វិសុទ្ធយាងមកសណ្ឋិតលើបងប្អូនម្នាក់ៗ ណែនាំឲ្យព្រះសហគមន៍យើងទាំងមូលលែងភ័យខ្លាចអ្វីទាំងអស់ ដោយសារយើងមានព្រះយេស៊ូគង់នៅជាមួយ។ ដូច្នេះសូមបងប្អូនអធិដ្ឋានឲ្យគ្នាទៅវិញទៅមក ឲ្យយើងចេះថែរក្សាគ្នា ឲ្យយើងស្វែងរកអ្នកដែលបោះបង់ព្រះសហគមន៍ អ្នកដែលបាត់បង់ជំនឿ និងឲ្យយើងចេះប្រកាសដំណឹងល្អជានិច្ច ប្រកាសពីជីវិតដែលយើងបានទទួលពីព្រះ ជាម្ចាស់ជាជីវិតសម្រាប់មនុស្សទាំងអស់។ យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ចំពោះព្រះយេស៊ូដែលគង់នៅជាមួយយើងខ្ញុំ។ សូមអរព្រះគុណព្រះជាម្ចាស់ ចំពោះព្រះវិញ្ញាណដ៏វិសុទ្ធដែលសណ្ឋិតលើបងប្អូនដែលទទួលអគ្គសញ្ញាលាប ថ្ងាសនៅថ្ងៃនេះ និងសូមព្រះគុណព្រះយេស៊ូដែលគង់នៅជាមួយបងប្អូនដែលទទួលព្រះកាយព្រះគ្រីស្តជាលើកទី១។ សូមអរព្រះគុណព្រះជាម្ចាស់ ដែលប្រោសឲ្យយើងខ្ញុំរួមគ្នាកសាងព្រះសហគមន៍។ អាម៉ែន។

# ការប្រជុំបូកសរុបការងារ



## របាយការណ៍បូកសរុបការងារក្នុងព្រះសហគមន៍មណ្ឌលសកម្មភាពកំពង់សោម ២២ មិថុនា ២០១៥

### 1. ក្រុមសង្គហៈ

មណ្ឌលសកម្មភាពកំពង់សោម កំពុងតែប្រព្រឹត្តយ៉ាងរលូនក្នុងកិច្ចការងាររបស់សង្គហៈបម្រើ និងជួយសង្គម។ ក្នុងនោះគឺមាន៣ចំណុច គឺទី១ កិច្ចការក្នុងសង្គម ទី២យើងមានការទំនាក់ទំនងល្អជាមួយគ្រូពេទ្យ ទី៣យើងមានទំនាក់ទំនងជាមួយអង្គការដៃគូរដែលពាក់ព័ន្ធនឹងការងារយើងធ្វើសព្វថ្ងៃនេះ។

a) កិច្ចការក្នុងសង្គម

កិច្ចការដែលយើងធ្វើនៅក្នុងឆ្នាំ២០១៤-២០១៥នេះ គឺទាក់ទងនឹងអ្នកជំងឺ អ្នកក្រីក្រ ស្រ្តីមេម៉ាយ និងក្មេងកំព្រា គឺពួកគាត់មានការអត់ឃ្លាន ភាពខ្វះខាត ទុក្ខលំបាកក្នុងជីវិតខ្លាំងមែនទែន។ ដូច្នេះក្រុមគណៈកម្មការយើង ចុះទៅជួបពួកគាត់ផ្ទាល់ ដើម្បីអប់រំណែនាំគាត់ និងលើកទឹកចិត្តគាត់គ្រប់បញ្ហាទាំងអស់ធ្វើឲ្យគាត់សប្បាយចិត្ត។

នៅក្នុងឆ្នាំ២០១៤នេះ អ្នកជំងឺដែលយើងបានបញ្ជូនគាត់ទៅមន្ទីរពេទ្យ មានចំនួន៩០នាក់ ហើយក្រុមគណៈកម្មការរបស់យើង បានចុះទៅសួរសុខទុក្ខបងប្អូនអ្នកជំងឺតាមផ្ទះមានចំនួន៤៨ដង។ ព្រះសហគមន៍យើង បានចុះទៅសួរសុខទុក្ខអ្នកជំងឺ នៅក្នុងមន្ទីរពេទ្យ និងមានអំណោយខ្លះៗជូនអ្នកជំងឺ

បានចំនួន៧០នាក់។ ព្រះសហគមន៍យើង បានផ្តល់គ្រែចំនួន២០សម្រាប់សម្រាលកូនដាក់ក្នុងមន្ទីរពេទ្យ។ យើងបានប្រមូលលុយ ដើម្បីទិញត្រីស្រស់ យកទៅជូនមន្ទីរពេទ្យសម្រាប់ធ្វើម្ហូបអាហារចែកជូនអ្នកជំងឺបានចំនួន៨០គីឡូផងដែរ។

b) ទំនាក់ទំនងល្អជាមួយគ្រូពេទ្យ

កិច្ចការងាររបស់យើងធ្វើទៅដោយលក្ខណៈងាយស្រួល ជាមួយនឹងគ្រូពេទ្យ ហើយគ្រូពេទ្យក៏បានផ្តល់ឱកាស សម្រាប់គណៈកម្មការយើងធ្វើការជាមួយគាត់សព្វបែបយ៉ាង។ ដូចជាបញ្ហាប្រឈមមុខជាមួយអ្នកជំងឺ ហើយអ្នកជំងឺខ្លះត្រូវទទួលការវះកាត់ជាបន្ទាន់ អ្នកជំងឺខ្លះត្រូវការបញ្ជូនទៅភ្នំពេញ ហើយអ្នកជំងឺខ្លះក៏មិនអាចព្យាបាលបាន គឺគ្រូពេទ្យជួយសម្រួលដល់យើង។ ព្រះសហគមន៍យើងក៏បានផ្តល់ម៉ាស៊ីនកាត់ស្មៅមួយគ្រឿងសម្រាប់ជួយការងារក្នុងមន្ទីរពេទ្យ។

c) ទំនាក់ទំនងជាមួយនឹងអង្គការដៃគូ

សព្វថ្ងៃព្រះសហគមន៍យើងខិតខំរិះរកអង្គការដៃគូ ដើម្បីរកដំណោះស្រាយមួយដ៏ល្អប្រសើរសម្រាប់ជួយជនក្រីក្រទាំងនោះ ដូចជាយើងសុំបណ្ណសមធម៌ជួយអ្នកជំងឺក្រីក្រ ដើម្បីទទួលព្យាបាលដោយឥតគិតថ្លៃ។ អង្គការដៃគូទាំងអស់នោះ គឺយើងសហការជាមួយគ្នាគ្រប់រឿងទាំងអស់ ពេលខ្លះយើងមានបញ្ហា យើងសុំយោបល់ យើងសំណូមពរ។ ពេលខ្លះក៏គេមានជួបឧបសគ្គ ហើយក៏ស្នើឲ្យយើង បញ្ជូនអ្នកជំងឺទៅភ្នំពេញដែរ។ ជារៀងរាល់ខែ គឺមានលោកវេជ្ជបណ្ឌិត សារឿន ចុះមកដើម្បីពិភាក្សាគ្នារកដំណោះស្រាយ ដើម្បីចុះសួរសុខទុក្ខជំងឺតាមសហគមន៍ផងដែរ។

សព្វថ្ងៃព្រះសហគមន៍ កំពុងធ្វើកិច្ចការជាច្រើនសម្រាប់បងប្អូនប្រជាជននៅតាមសហគមន៍ជាពិសេសចំពោះយុវជននៅក្នុងសហគមន៍ ដោយបានផ្តល់អាហារូបករណ៍ បង់ថ្លៃរៀនសូត្រនិងការស្នាក់នៅ និងជួយជនក្រីក្រដែលគ្មានផ្ទះសម្បែងឲ្យមកស្នាក់នៅព្រះសហគមន៍យើងផងដែរ។

អំណោយខ្លះៗដែលយើងបានវិចខ្ចប់ជូនបងប្អូននិងជួយជនក្រីក្រ បានមកពីសប្បុរសជនដែលបានចូលរួមចំណែកជាមួយព្រះសហគមន៍ដើម្បីជួយក្នុងសង្គម។ នេះជាមោទនភាពមួយសម្រាប់ព្រះសហគមន៍យើង ដោយមានលោកបូជាចារ្យអ៊ុន សុន ជាអ្នកជួយជំរុញ ហើយនិងបំពេញការងារទទួលខុសត្រូវក្នុងព្រះសហគមន៍ ។

2. **ក្រុមអប់រំជំនឿ និងក្រុមពិធីបុណ្យ**

ព្រះសហគមន៍យើងជារៀងរាល់អាទិត្យ តែងតែមានសកម្មភាពជួយណែនាំការអប់រំជំនឿដល់ប្អូនៗ។ យើងមានបងប្អូនជាច្រើន គាត់បានទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងឆ្នាំកន្លងមក។ សកម្មភាព

នៃការអប់រំជំនឿក្នុងឆ្នាំ២០១៤ និង២០១៥ យើងមានរហូតដល់ទៅ៥ក្រុម មានថ្នាក់ត្រៀមជំហានទី១ ថ្នាក់ត្រៀមទទួលអគ្គសញ្ញាលាបថ្ងាស ថ្នាក់ត្រៀមទទួលព្រះគម្ពីរ ថ្នាក់ត្រៀមទទួលអគ្គសញ្ញាព្រះកាយព្រះគ្រីស្ត និងថ្នាក់កុមារតូចៗ។

ព្រះសហគមន៍យើងធ្វើការជាមួយសង្គម យើងមានទំនាក់ទំនងល្អជាមួយអន្តរសាសនា។ នៅចុងឆ្នាំ២០១៤ យើងបានជូនកុំព្យូទ័រមួយគ្រឿងដល់មន្ទីរអន្តរសាសនា។ ហើយសព្វថ្ងៃក៏យើងបានសហការជាមួយអង្គការCCS។ ជារៀងរាល់ឆ្នាំអង្គការ CCS មានគម្រោងមួយសម្រាប់ជួយដល់សិស្សក្នុងមណ្ឌល និងសាលាមត្តេយ្យដូចជាផ្តល់ជាថវិការខ្លះសម្រាប់ធ្វើម្ហូបអាហារ និងថវិកាសម្រាប់គ្រូផងដែរ។ យើងសហការជាមួយគ្នាបានយ៉ាងល្អ។

សម្រាប់ពិធីបុណ្យយើងចែកតាមវេននីមួយៗជារៀងរាល់សប្តាហ៍ ដូចជា ក្រុមយុវជន១ក្រុម ក្រុមអប់រំជំនឿ១ក្រុម ក្រុមសង្គហៈ១ក្រុម ក្រុមពិធីបុណ្យ១ក្រុម និងក្រុមកុមារៗ១ក្រុម ដូច្នេះយើងធ្វើតាមអាទិត្យនីមួយៗ ដោយដូរវេនវិលជុំ។

3. **ក្រុមយុវជន**

នៅក្នុងព្រះសហគមន៍យើងមានយុវជនច្បាស់លាស់ ដើម្បីរៀបចំកម្មវិធីផ្សេងៗ នៅក្នុងបេសកកម្មរបស់ព្រះយេស៊ូ។ ព្រះសហគមន៍យើងចែកជាបួនសកម្មភាពក្នុងមួយខែ សប្តាហ៍ទី១ យើងជួបជុំគ្នារិះគិតអំពីបញ្ហាសម្រាប់ដោះស្រាយ សប្តាហ៍ទី២ យើងធ្វើការចុះទៅតាមភូមិ ជួបអ្នកក្រីក្រ សប្តាហ៍ទី៣ យើងសម្អាតបរិស្ថាននៅជុំវិញព្រះសហគមន៍យើង សប្តាហ៍ទី៤ យើងទំនាក់ទំនងជាមួយក្រុមផ្សេងៗដើម្បីរកជំនួយសប្បុរសធម៌។

4. **ក្រុមវាំងសង់ដីប៉ូល**

ក្រុមវាំងសង់ដីប៉ូលយើងមានគ្នា៥៣នាក់ យើងបានរកជំនួយ ដូចជាអង្ករ ជាលុយ សម្រាប់ឧបត្ថម្ភដល់សិស្សក្រីក្រ និងចិញ្ចឹមចាស់ជរាតាមភូមិ។ ក្នុងមួយឆ្នាំម្តង ក្រុមយើងខ្ញុំបានផ្តល់ បន្ទប់ទឹក អណ្តូងទឹក ធ្វើផ្ទះដល់អ្នកក្រីក្រតាមភូមិ។

5. **ផ្សេងៗ**

ព្រះសហគមន៍មណ្ឌលសកម្មភាពកំពង់សោម យើងបានទទួលជំនួយបានសាលាមត្តេយ្យ៣កំពុងសាងសង់ និងកំពង់ដំណើរការ មានមួយនៅស្រែអំបិល មួយនៅភូមិកំពង់ពារ ដែលបានទទួលអំណោយដីពីអ្នកភូមិ និងព្រះសហគមន៍ជួយសាងសង់អគារ ដែលបានដំណើរការ៣ឆ្នាំហើយ។ លោកបូជាចារ្យមកពីប៊ែលហ្សិក ជួយសាងសង់សាលានៅត្រែងត្រយឹង។ សូមបញ្ជាក់ផង

ដែរថា ប្រាក់តង្វាយដែលយើងបានទទួលពីព្រះសហគមន៍ផ្សេងៗ នៅក្នុងមណ្ឌលសកម្មភាពកំពង់សោម យើងយកទៅជួយសាលាមត្តេយ្យទាំងអស់។ យើងមានជំនួយពីអង្គការកុមារមេត្តា គឺជួយអាហាររូបករណ៍សិស្សបានចំនួន១២នាក់។ យើងបានជំនួយពីប្រទេសកូរ៉េចំនួន៤ឆ្នាំហើយ គឺជួយអាហាររូបករណ៍សិស្ស២នាក់ទៅរៀននៅប្រទេសកូរ៉េ។ យើងក៏បានជំនួយពីបាជី នូវសម្ភារ១០០កញ្ចប់ ហើយកន្លងមកយើងបានចែកទៅតាមកន្លែងផ្សេងៗ ដូចជានៅតាមផ្ទះខ្លះ និងទៅតាមភូមិខ្លះ។ យើងបានទទួលអង្ករចំនួន២តោនពីក្រុមហ្វង់ស៊ីស្កូ (ហ្វាងស៊ីស្កូ) ដែលយើងក៏បានចែកទៅតាមព្រះសហគមន៍ក្នុងមណ្ឌល ដើម្បីចែកជូនអ្នកក្រីក្រ។ យើងមានសប្បុរសជនមកពីអាមេរិក បានជួយយកចិត្តទុកដាក់ធ្វើសាលារៀនសម្រាប់កុមារ។ យើងមានក្រុមបងស្រីក៏បានជួយច្រើនដែរពិសេសសាលានៅភូមិកំពង់ពារ។ នៅបុណ្យចម្លង យើងមានចែកដបសម្រាប់ដាក់លុយដើម្បីសន្សំជួយសាលា។ នៅក្នុងខែតុលាពេញមួយខែ យើងមានអធិដ្ឋានតាមផ្ទះ និងចែកព្រះកាយដែរ។

6. **សំណូមពរ**

- *អប់រំជំនឿជាភាសាវៀតណាមនៅតាមព្រះសហគមន៍ដែលកុមារៗមិនចេះភាសាខ្មែរ*
- *ទិញបច្ច័សម្រាប់បូជាសពនៅកោះខ្សង ឬបឹងតាព្រហ្ម*
- *ឲ្យមានកិច្ចសហការគ្នារវាងគណៈកម្មការនិងយុវជន ដើម្បីបន្តវេនធ្វើកិច្ចការគ្រីស្តទូត*
- *នៅតាមព្រះសហគមន៍ យើងគួរតែមានសមាគមសម្រាប់អ្នកស្លាប់ ដើម្បីប្រមូលលុយជួយក្រុមគ្រួសារដែលស្លាប់ ដោយមានបង់ជាវិភាគទានជារៀងរាល់ខែជាដើម។*
- *ជួយសម្រួលមធ្យោបាយធ្វើដំណើរដល់យុវជននៅត្រែងត្រយឹងក្នុងការចុះតាមភូមិ។*
- *គណៈកម្មការសង្គហៈ សូមសហការគ្នាផ្នែកសុខភាព ដោយសូមឲ្យប្រាប់ជាមុនដើម្បីស្រួលចុះបញ្ជីចំនួន មនុស្ស ក្នុងការធ្វើរបាយការណ៍ជម្រាបជូនក្រសួងសុខាភិបាល។*
- *យើងនៅពីរកន្លែងទៀតដែលយើងចោល គឺមាននៅអណ្តូងទឹក និងនៅកោះស្តេច សូមកសាងព្រះសហគមន៍ឡើងវិញនៅទីនោះ។*
- *រកពេលមួយដើម្បីឲ្យក្រុមយុវជនក្នុងមណ្ឌលសកម្មភាពទាំងមូលជួបជុំគ្នាឡើងវិញ ដើម្បី រកគំនិតថ្មីៗក្នុងកសាងព្រះសហគមន៍។*

រៀបចំដោយ

## ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក ( ភូមិភាគភ្នំពេញ )


#25, St.242, Sangkat Boeung Prolit, Khan 7 Makara, Phnom Penh City

Tel: 023 224 120

Website: www.catholicphnompenh.org

Facebook page: Catholic Phnom Penh

E-mail: catholicphnompenh@gmail.com


Formation, Dialogue, Cooperation

